# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៣៩ ស្តីពីការតែងតាំងលោក **សួន សុផល** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២០៦៥

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៦ ស្តីពីការតែងតាំងលោក **ឃួន តិរុណា** ជា **ឧកញ៉ា** ២០៦៦

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៤៨ ស្តីពីការប្រោសព្រះរាជទាន ប្រគេនព្រះពុទ្ធវង្ស **គ្រួច សារ៉េត** នូវគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ២០៦៧

២១-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៥០ ស្តីពីការតែងតាំងលោក **នួន សុភ័ណ្ឌ** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ២០៦៨

២៦-៣-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៣០៥/១៥៩ ស្តីពីការប្រោសព្រះរាជទាន ប្រគេនព្រះតេជគុណ **កែច សម្បត្តិ** នូវគ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ២០៦៩

០១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៤ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ចយ ដុងស៊ីក** (CHOI DONG SHIK) សញ្ជាតិកូរ៉េ កើតនៅក្រុងក្វាងហ្សូ ប្រទេសកូរ៉េ ២០៧០

០១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៥ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឧកញ៉ា **ចាយ ស៊ាងអ៊ី** នូវគ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ២០៧១

០១-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៦ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ ចំនួន ១៣ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ២០៧២

០២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៧ ស្តីពីការតម្លើងឋានន្តរស័ក្តិ ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល ២០៧៤

០២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៨ ស្តីពីការតែងតាំង ឯកឧត្តម **ម៉ូ ម៉ារ** ជា **អគ្គាធិការ** នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ ២០៧៧

០២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៦៩ ស្តីពីការបំពាក់គ្រឿងឥស្សរិយយស **ការពារជាតិ** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ២០៧៨

០២-៤-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៤០៥/១៧១ ស្តីពីការតែងតាំងទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រី កិត្តិយស នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល ២០៨១


## II-រាជរដ្ឋាភិបាល

## អនុក្រឹត្យ


០១-៤-២០០៥ -អនុក្រឹត្យលេខ ៥៣ អនក្រ.បក ស្តីពីនីតិវិធី ការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជិកា សម្បត្តិព្រៃឈើអចិន្ត្រៃយ៍ ២០៩៩

០៨-៤-២០០៥ -អនុក្រឹត្យលេខ ៥៤ អនក្រ.បក ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុង អាជីវកម្មអគ្គិសនី ២១០៥

០៨-៤-២០០៥ -អនុក្រឹត្យលេខ ៥៥ អនក្រ.បក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ២១១៥

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២១៣០

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២១៣១

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៣៣

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៣៥

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២១៣៧

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៣៨

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៤០

០១-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៤១

០៤-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៤២

០៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៤៤

០៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៤៥

០៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពីការដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ ២១៤៦
០៦-៤-២០០៥ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ២១៤៨
០៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៥០
០៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៥២
០៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៤ អនក្រ.តត ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ២១៥៣
០៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១៥៥
០៧-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៦ អនក្រ.តត ស្តីពីការជូនមេដាយការងារ ២១៥៧
០៨-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៥៩
០៨-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់ ២១៦០
០៨-៤-២០០៥ -អនុក្រឹត្យលេខ ៣៦៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៦១
០៨-៤-២០០៥ -អនុក្រឹត្យលេខ ៣៧០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១៦៣

## III~ទីស្តីការគណៈរដ្ឋមន្ត្រី

០៦-៤-២០០៥ -សេចក្តីសំរេចលេខ ១៩ សសរ.កបច ស្តីពីការកែសម្រួលលេខាធិការដ្ឋាន គណៈកម្មការបណ្ឌិតសភា ទទួលបន្ទុកអនុម័តពាក្យច្បាប់ ២១៦៥

## IV~ការិយាល័យក្រសួង

## ១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០១-៤-២០០៥ -ប្រកាសលេខ ១៩៣ សហវ.ប្រក ស្តីពីការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង ២១៦៧-ក
០១-៤-២០០៥ -ប្រកាសលេខ ១៩៤ សហវ.ប្រក ស្តីពីការរំសាយការិយាល័យសវនកម្មផ្ទៃក្នុងរបស់ នាយកដ្ឋានពន្ធដារ ២១៦៨
០៤-៤-២០០៥ -ប្រកាសលេខ ១៩៨ សហវ.ប្រក ស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យ សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ២១៧០
០៤-៤-២០០៥ -ប្រកាសលេខ ១៩៩ សហវ.ប្រក ស្តីពីការបង្កើតគណៈកម្មការការងារ សិក្សា និងស្រាវជ្រាវសំរាប់វិទ្យាស្ថានគណនេយ្យករជំនាញ និង សវនករកម្ពុជា ២១៧៨

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


២២-៣-២០០៥ -លិខិតលេខ ៦៤២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ថាន អាន អ៊ិនដាស្ទ្រី ខូអបពើរេសិន** ២១៨១

២៤-៣-២០០៥ -លិខិតលេខ ៦៨៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**បូផា ខិនណេកសិន ត្រាវ៉ែល** ២១៨៣

២៤-៣-២០០៥ -លិខិតលេខ ៦៨៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិល អេ អ៊ីមផត អិចផត** ២១៨៥

២៤-៣-២០០៥ -លិខិតលេខ ៦៨៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អេច.អាយ.អេស (ខេមបូឌា) ត្រាវ៉ែល** ២១៨៧

២៥-៣-២០០៥ -លិខិតលេខ ៦៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**កានសាន សូទិច ម៉ាស៊ីន** ២១៨៩

២៥-៣-២០០៥ -លិខិតលេខ ៦៩២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឃុល វ៉ាន់លីន អ៊ីន** ២១៩១

២៨-៣-២០០៥ -លិខិតលេខ ៦៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សេង ស្រស់ ខនស្ត្រាក់សិន ខូ អិលធីឌី** ២១៩៣

២៨-៣-២០០៥ -លិខិតលេខ ៦៩៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិន.ប៊ី.អេស អ៊ិនធើណេសិនណល ខនសាល់ធេន គ្រុប** ២១៩៥

២៨-៣-២០០៥ -លិខិតលេខ ៧០០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ចុង ស៊ីង អ៊ិនដាសស្ទ្រៀល អ៊ិនវេសមេន (ខេមបូឌា)** ២១៩៧

២៨-៣-២០០៥ -លិខិតលេខ ៧០១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**អិម ប៊ី ខេ ប្រូដាក់** ២១៩៩

២៩-៣-២០០៥ -លិខិតលេខ ៧១៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ផារីដាវៀងរិត្ត ខនស្ត្រាក់សិន & ឌីវេឡុបមេន** ២២០១

២៩-៣-២០០៥ -លិខិតលេខ ៧១៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**មីកាវេ (ខេមបូឌា) អ៊ីមផត អិចផត** ២២០៣

២៩-៣-២០០៥ -លិខិតលេខ ៧១៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី ប៊ី អូ ឌីវេឡុបមេន ខូអបភើរេសិន** ២២០៥

២៩-៣-២០០៥ -លិខិតលេខ ៧១៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេមបូឌីល ខនស្ត្រាក់សិន ខេមីខល** ២២០៧

៣០-៣-២០០៥ -លិខិតលេខ ៧១៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ធី.លីមីុច** ២២០៩

៣០-៣-២០០៥ -លិខិតលេខ ៧១៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **បេស យូរ** ២២១១

៣០-៣-២០០៥ -លិខិតលេខ ៧២០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេនឡូ អ៊ីមផត អិចផត ហ្វើនីឈើរ** ២២១៣

៣០-៣-២០០៥ -លិខិតលេខ ៧២១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អែគោ ឆូរ** ២២១៥

៣០-៣-២០០៥ -លិខិតលេខ ៧២២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **យូនៀន គេត្រូឈៀម** ២២១៧

០៤-៤-២០០៥ -ប្រកាសលេខ ១៣១ MOC/M2005 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរមួយចំនួននៅកម្ពុជា ២២១៩

០៤-៤-២០០៥ -ប្រកាសលេខ ១៣២ MOC/M2005 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរមួយចំនួននៅកម្ពុជា ២២២១


## ៣-ឯកសារក្រសួងអប់រំ យុវជន និង កីឡា


០១-៤-២០០៥ -ប្រកាសលេខ ៤៨០ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ទ័ពស្រូវ ស្ថិតនៅក្នុងឃុំបន្ទាយព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ២២២៣

០១-៤-២០០៥ -ប្រកាសលេខ ៤៨១ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ដារ ស្ថិតនៅក្នុងឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ២២២៤

០១-៤-២០០៥ -ប្រកាសលេខ ៤៨២ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ តាំងក្រសាំង ស្ថិតនៅក្នុង ឃុំតាំងក្រសាំង ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ២២២៥

០១-៤-២០០៥ -ប្រកាសលេខ ៤៨៣ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ទួលខ្ពស់ ស្ថិតនៅក្នុងឃុំទួលខ្ពស់ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ២២២៦

| | | |
|---|---|---|
| ០១-៤-២០០៥ | -ប្រកាសលេខ ៤៨៤ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ប្រពេជចង្វារ ស្ថិតនៅក្នុងឃុំពេជចង្វារ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ២២២៧ |
| ០១-៤-២០០៥ | -ប្រកាសលេខ ៤៨៥ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ព្រៃមូល ស្ថិតនៅក្នុងឃុំព្រៃមូល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២២២៨ |
| ០១-៤-២០០៥ | -ប្រកាសលេខ ៤៨៦ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ទឹកហូត ស្ថិតនៅក្នុងឃុំទឹកហូត ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២២២៩ |
| ០១-៤-២០០៥ | -ប្រកាសលេខ ៤៨៧ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ កោះថ្កូវ ស្ថិតនៅក្នុងឃុំកោះថ្កូវ ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង | ២២៣០ |
| ០១-៤-២០០៥ | -ប្រកាសលេខ ៤៨៨ អយក.ប្រក ស្តីពី ការបើកអនុវិទ្យាល័យ ព្រះធាតុ ស្ថិតនៅក្នុងឃុំពង្រ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២២៣១ |

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/ ១៣៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោក សួន សុផល ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ - ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

តរល-០៥០៣-១៤៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០០៥*

លេខៈ ១៤២ . ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible]**

នស/រកត/០៣០៥/១៤៦

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា )

**តែងតាំង**

លោក ឃួន គីរុណា

ជា

ឧកញ៉ា

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

៣រស-០៥០៣-១៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មីនា ឆ្នាំ ២០០៥

លេខ [illegible] ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible]**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៤៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្សិរីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ប្រគេន

ព្រះពុទ្ធវង្ស គ្រួច សារ៉េត

នូវ

គ្រឿងឥស្សរិយយស មុនីសារាភិវឌ្ឍ ថ្នាក់ មហាសេនា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៤០៣.១៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥

B.106

លេខ ...៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

42

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៥០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោក នួន សុវត័ណ្ឌ ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

**មាត្រា ២ :** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៣.១៥៦

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៥*

លេខ: ១៤១ ច.ល
**បានចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៥
**[illegible]រាជរដ្ឋាភិបាល**
**[illegible] តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៣០៥/១៥៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ប្រគេន

ព្រះតេជគុណ កែម សម្បត្តិ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៥០៣.១៦៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៥

លេខ ៖ ១៥០. ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សោមី តាន់

ឧ.អ

នស/រកត/០៤០៥/១៦៤

# ព្រះរាជក្រឹត្យ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ ៖** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ឈយ ដុងស៊ីក** ( CHOI DONG SHIK ) សញ្ជាតិកូរ៉េ កើតថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៥៦ នៅក្រុងក្វាងហ្ស៊ូ ប្រទេសកូរ៉េ ។

**មាត្រា ២ ៖** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ ៖** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៤.១៧០

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៥*

លេខ ១៥០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ.ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**[illegible] តាន់**

នស/រកត/០៤០៥/១៦៥

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

ឧកញ៉ា **ចាយ ស៊ាងអ៊ី**

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥០៤.១៧១

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ.ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥*

B.103

លេខ [illegible] - ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឧណាទី តាន់**

នស/រកត/០៤០៥/១៦៦

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ៈ** បំពាក់គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនមន្ត្រីជាន់ខ្ពស់ ចំនួន១៣រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

**ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :**

-ឯកឧត្តម **ចាន់ សារុន** រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :**

-ឯកឧត្តម **ចាន់ តុងអ៊ីវ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :**

១-ឯកឧត្តម **តេង ឡៅ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

២-ឯកឧត្តម **អ៊ុក សុខុន** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៣-ឯកឧត្តម **មាស គឹមសុវ៉ារ៉ូ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៤-ឯកឧត្តម **អ៊ិត ណូឌី** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

៥-ឯកឧត្តម **ទី សុគន្ធ** ប្រធានរដ្ឋបាលព្រៃឈើ

៦-ឯកឧត្តម **អ៊ឹង ហុកលីម** អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**ឃ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :**

១-ឯកឧត្តម **ចាន់ ណារ៉េត** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម
២-ឯកឧត្តម **ឈី ផល្លា** អគ្គនាយក នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
៣-លោក **ខឹម ខួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានចំការកៅស៊ូ
៤-លោក **ផាត់ មុនី** នាយកសាលាជាតិ កសិកម្ម ព្រែកលៀប
៥-លោក **ទៅ ម៉ិនថាន** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

**មាត្រា២ :** សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស.០៥០៤.១៧២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥*

លេខ ១៤៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ឈាអ៊ី តាន់**

B 134

នស/រកត/០៤០៥/១៦៧

# ព្រះរាជក្រឹត្យ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិសារ្ត្ត ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម **សំដៅធានានូវ**ដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០២/២៩២ ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០២ ស្តីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល



2/4

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១០៣/០២០ ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៣ ស្ដីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២១១ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៣ ស្ដីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/១៧៤ ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៤ ស្ដីពីការធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិល ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ —**

ត្រូវបានតម្លើងឋានន្តរស័ក្តិ ពីឋានន្តរស័ក្តិវរមន្ត្រី ទៅឋានន្តរស័ក្តិឧត្ដមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័ន មានដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| | **ក្រសួងអប់រំ យុវជន និង កីឡា** | | |
| ១ | ឯកឧត្ដម **អ៊ឹង ថុង** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| | **ក្រសួងពត៌មាន** | | |
| ២ | ឯកឧត្ដម **គន់ យ៉ាន** | **ពីវរមន្ត្រី**ថ្នាក់លេខ ៤ | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| | **ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍** | | |
| ៣ | ឯកឧត្ដម **គុយ ពុំ** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| ៤ | ឯកឧត្ដម **ព្រំ សុន្ធរ** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| ៥ | ឯកឧត្ដម **នូច ហេង** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| | **ក្រសួងបរិស្ថាន** | | |
| ៦ | ឯកឧត្ដម **ឆា ជុប** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |
| ៧ | ឯកឧត្ដម **ឈរ ថាវណារ** | **ពីវរមន្ត្រី**ថ្នាក់លេខ **៥** | ទៅ**ឧត្ដមមន្ត្រី**ថ្នាក់លេខ **៥** |



3/4

| | | | |
|---|---|---|---|
| | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច | | |
| ៨ | ឯកឧត្តម ឆេង សារឿន | ពីវរមន្ត្រីថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥ |
| | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | | |
| ៩ | ឯកឧត្តម ចៅ សេដ្ឋាណា | ពីវរមន្ត្រីថ្នាក់លេខ ៥ | ទៅឧត្តមមន្ត្រីថ្នាក់លេខ ៥ |

**មាត្រា ២ –**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ –**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ –**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នរល-០៥០៤-១៧៣*

ធ្វើនៅព្រះបរមរាជវាំង,រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ *មេសា* ឆ្នាំ ២០០៥

លេខ ១៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ តាន់**

នស/រកត/០៤០៥/១៦៨

# ព្រះរាជក្រឹត្យ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងផែនការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម ហ៊ូ ឃួរ ជា **អគ្គនាយក** នៃអគ្គាធិការដ្ឋាន របស់ក្រសួងផែនការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤-០៥០៤.១៧៤

*ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ .ថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០០៥*

លេខ ១៤៥ ច.ល
ជំនួសឲ្យច្បាប់ដើម
រាជធានីភ្នំពេញ.ថ្ងៃទី ខែ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

/2

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/១៦៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្សាខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
## ខេមរជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : បំពាក់ **គ្រឿងឥស្សរិយយស ការពារជាតិ** ជូននាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០២រូប ក្នុងមួយរូប១ មាស ០២គ្រឿង ប្រាក់ ០២គ្រឿង និង សំរិទ្ធ ០២គ្រឿង ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី **មាស ផ្លា** | អត្តលេខ ០០៤៣១៥ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ត្រី **ពេជ្រ សូជេត្ថា** | អត្តលេខ ០០៤៣២០ | អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ |

**មាត្រា២** : បំពាក់ **គ្រឿងឥស្សរិយយស ការពារជាតិ** ជូននាយទាហាន ជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៤៨រូប ក្នុងមួយរូប១ មាស ០១គ្រឿង ប្រាក់ ០១គ្រឿង និង សំរិទ្ធ ០១គ្រឿង ដូចមានរាយនាមខាងក្រោម :-

| | | |
|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី **តាន់ ចំណា** | អត្តលេខ ០០១៤៥១ | នាយក នាយកដ្ឋានផ្គត់ផ្គង់ |
| ២-ឧត្តមសេនីយ៍ត្រី **ឆេក សំអាន** | អត្តលេខ ០០០៦៧៥ | នាយករង នាយកដ្ឋានអប់រំ |
| ៣-ឧត្តមសេនីយ៍ត្រី **គន្ធ ភារាចណ្ណ** | អត្តលេខ ០០១៣១៥ | នាយករង នាយកដ្ឋានអប់រំ |
| ៤-ឧត្តមសេនីយ៍ត្រី **ចាប សំរិទ** | អត្តលេខ ០០០៧៤១ | នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ |
| ៥-ឧត្តមសេនីយ៍ត្រី **គិន សុខ** | អត្តលេខ ០០០៥៨៨ | នាយករង នាយកដ្ឋានសោធននិវត្តន៍ |
| ៦-ឧត្តមសេនីយ៍ត្រី **នួន ឈារិន** | អត្តលេខ ០០១១០១ | ទីប្រឹក្សា អគ្គមេបញ្ជាការ |
| ៧-ឧត្តមសេនីយ៍ត្រី **អ៊ុំ ម៉ារ៉ា** | អត្តលេខ ០០១១២៨ | នាយករង នាយកដ្ឋាននយោបាយផែនការ |
| ៨-ឧត្តមសេនីយ៍ត្រី **ឈុម រតនា** | អត្តលេខ ០០១៨៨១ | នាយករង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន |

៩-ឧត្តមសេនីយ៍ត្រី ម៉ុច សុទី អត្តលេខ ០០២៣៥០ នាយករង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

១០-ឧត្តមសេនីយ៍ត្រី ឃុត ឆេ អត្តលេខ ០០២០០២ នាយករងទីចាត់ការឃោសនាពត៌មាន អគ្គបញ្ជាការដ្ឋាន

១១-ឧត្តមសេនីយ៍ត្រី គីម ផាន់ណា អត្តលេខ ០០០៧២២ នាយករង ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការដ្ឋាន

១២-ឧត្តមសេនីយ៍ត្រី សោម ជន អត្តលេខ ០០១០៨៩ នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

១៣-ឧត្តមសេនីយ៍ត្រី សំ ចន្ធូនី អត្តលេខ ០០០៦៦៧ នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

១៤-ឧត្តមសេនីយ៍ត្រី នាត ធឿន អត្តលេខ ០០០៤០៣ នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

១៥-ឧត្តមសេនីយ៍ត្រី គង់ ចន្ថា អត្តលេខ ០០១៩៣៩ នាយសេនាធិការរងសេនាធិការដ្ឋានកងអន្តរាគមន៍

១៦-ឧត្តមសេនីយ៍ត្រី សូ ឈារ៉ា អត្តលេខ ០០៤៤១០ មេបញ្ជាការរងកងទ័ពជើងអាកាស ទទួលបន្ទុកបច្ចេកទេស

១៧-ឧត្តមសេនីយ៍ត្រី ផាន់ នរិទ្ធ អត្តលេខ ០០៤៤០៨ មេបញ្ជាការរងកងទ័ពជើងអាកាស ទទួលបន្ទុកយន្តហោះស្ទាប

១៨-ឧត្តមសេនីយ៍ត្រី ទុំ សុភាព អត្តលេខ ០០០៨៥៣ មេបញ្ជាការរង យោធភូមិភាគពិសេស

១៩-ឧត្តមសេនីយ៍ត្រី ខាំ ផាយ អត្តលេខ ០០០៣៩៤ មេបញ្ជាការរង យោធភូមិភាគទី ១

២០-ឧត្តមសេនីយ៍ត្រី សេង សារម៉ឿន អត្តលេខ ០០០៤១១ មេបញ្ជាការរង យោធភូមិភាគទី ២

២១-ឧត្តមសេនីយ៍ត្រី ទឹម សុខ អត្តលេខ ០០០៦១១ នាយករង នាយកដ្ឋាន វិស្វកម្ម

២២-ឧត្តមសេនីយ៍ត្រី ជា ម៉េង អត្តលេខ ០០០៦១៩ នាយករង នាយកដ្ឋាន សុខាភិបាល

២៣-ឧត្តមសេនីយ៍ត្រី នាង ភាវ៉ៃ អត្តលេខ ០០១៩៧៨ នាយករង នាយកដ្ឋាន ពត៌មាន

២៤-ឧត្តមសេនីយ៍ត្រី សុត ធុន្នី អត្តលេខ ០០០៥០២ នាយករង នាយកដ្ឋាន អធិការកិច្ចទូទៅ

២៥-ឧត្តមសេនីយ៍ត្រី ជោក សុផា អត្តលេខ ០០២០២១ នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនភាសាបរទេសនិង ចំណេះទូទៅ វិទ្យាស្ថានយោធាកម្ពុជា

២៦-ឧត្តមសេនីយ៍ត្រី ថាច់ ម៉ីនា អត្តលេខ ០០១២០២ នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនយុទ្ធសាស្ត្រយោធា និង ចំណេះទូទៅ វិទ្យាស្ថានយោធាកម្ពុជា

២៧-ឧត្តមសេនីយ៍ត្រី សោម សាលី អត្តលេខ០០២២៥១ នាយករង វិទ្យាស្ថានយោធាកម្ពុជា

២៨-ឧត្តមសេនីយ៍ត្រី គីម ម៉ាន់សារ៉ុម អត្តលេខ ០០២២៤០ នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនបញ្ជាការសេនាធិការ វិទ្យាស្ថានយោធាកម្ពុជា

២៩-ឧត្តមសេនីយ៍ត្រី សៅ សៀប អត្តលេខ ០០១៩៨៩ នាយករង ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន

៣០-ឧត្តមសេនីយ៍ត្រី សេខ ឌុល្លី អត្តលេខ ០០១១៨១ នាយករង ខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន

៣១-ឧត្តមសេនីយ៍ត្រី អ៊ុន ភិន អត្តលេខ ០០០៤៨៩ ទីប្រឹក្សា អគ្គមេបញ្ជាការ

៣២-ឧត្តមសេនីយ៍ត្រី គួច ឡាយ អត្តលេខ ០០០៦៨០ ទីប្រឹក្សា អគ្គមេបញ្ជាការ

៣៣-ឧត្តមសេនីយ៍ត្រី គង់ ចណ្ឌី អត្តលេខ ០០២៥១៤ លេខា ឯកឧត្តម ម៉ុល សារឿន

៣៤-ឧត្តមសេនីយ៍ត្រី ចៀត ថា អត្តលេខ ០០១៣៧៤ ប្រធានក្រុមការពារថ្នាក់ដឹកនាំ និងជាមេបញ្ជាការ រងកងរាជអាវុធហត្ថ រាជធានីភ្នំពេញ

៣៥-ឧត្តមសេនីយ៍ត្រី វៀម និត្យ អត្តលេខ ០០១០៨៣ មេបញ្ជាការរង កងពលតូចលេខ ៧០

៣៦-ឧត្តមសេនីយ៍ត្រី ចាន់ ចន្ថា អត្តលេខ ០០២៣១៨ មេបញ្ជាការរង កងពលតូចលេខ ៧០

៣៧-ឧត្តមសេនីយ៍ត្រី ជួន សារី អត្តលេខ ០០០៤៤៧ មេបញ្ជាការរង កងពលតូចលេខ ៧០

៣៨-ឧត្តមសេនីយ៍ត្រី ឈុន ម៉ឿន អត្តលេខ ០០២៣៦០ មេបញ្ជាការរង កងពលតូចលេខ ៧០

៣៩-ឧត្តមសេនីយ៍ត្រី ម៉ែម ខាំ អត្តលេខ ០០០៤៤២ មេបញ្ជាការរង កងពលតូចលេខ ៧០

៤០-ឧត្តមសេនីយ៍ត្រី ឈឿន ចាន់ថន អត្តលេខ ០០៣៣៦១ មេបញ្ជាការរង កងពលតូចលេខ៧០ និង ជាមេបញ្ជាការ វរសេនាតូចលេខ១ អង្គរក្ស សម្តេច ជា ស៊ីម

៤១-ឧត្តមសេនីយ៍ត្រី អ៊ិត សាខន អត្តលេខ ០០០៣៧៤ ឧបការី សម្តេចក្រុមព្រះ

៤២-ឧត្តមសេនីយ៍ត្រី រស់ សុន្ទ អត្តលេខ ០០០៣៧៨ លេខា ឯកឧត្តម ញឹក ប៊ុនឆៃ

៤៣-ឧត្តមសេនីយ៍ត្រី សុខ សុខៈ អត្តលេខ ០០០៤៧៤ ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី

៤៤-ឧត្តមសេនីយ៍ត្រី ហេង សារឿន អត្តលេខ ០០០៤៧៣ ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី

៤៥-ឧត្តមសេនីយ៍ត្រី សេង សុខ អត្តលេខ ០០០៤៤៦ មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស និង ជាមេបញ្ជាការ កងរាជអាវុធហត្ថ រាជធានីភ្នំពេញ

៤៦-ឧត្តមសេនីយ៍ត្រី សូ សុខវណ្ណមុនី អត្តលេខ ០០០៧៨៧ មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

៤៧-ឧត្តមសេនីយ៍ត្រី វ៉េង រ៉ា អត្តលេខ ០០០៨០៣ មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

៤៨-ឧត្តមសេនីយ៍ត្រី នួន សំអាន អត្តលេខ ០០២១៥៦ មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការដ្ឋាន

**មាត្រា៣** : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ពរល.០៥០៤.១៧៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៥*

លេខ ១៤៨ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខី តាន់**

B.132

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៥/១៧១

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរាជ្ជរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងទៅក្នុងឋានន្តរស័ក្តិឧត្តមមន្ត្រីកិត្តិយស នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នូវមន្ត្រីរាជការស៊ីវិល ដូចមានរាយនាមខាងក្រោម :

១ - ឯកឧត្តម **ស៊ុំ ម៉ានិត** ឧត្តមមន្ត្រី ថ្នាក់លេខ ១

២ - ឯកឧត្តម **ហុង ថែម** ឧត្តមមន្ត្រី ថ្នាក់លេខ ១

៣ - ឯកឧត្តម **ជិន គីមស្រេង** ឧត្តមមន្ត្រី ថ្នាក់លេខ ១

៤ - ឯកឧត្តម ខួន វ៉ាន់ឌី ឧត្តមមន្ត្រី ថ្នាក់លេខ ១

៥ - លោកជំទាវ ឆី ឫទ្ធិរ៉ាស៊ី ឧត្តមមន្ត្រី ថ្នាក់លេខ ១

**មាត្រា ២ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នរក.០៥០៤.១៧៧

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០៥*

លេខ ១៤៥ ច.ល

**ដើម្បីចម្លងចែកចាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៥

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ
## របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៥

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្ដាអង្គភាពនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្ដាអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួង ។

## ជំពូកទី ២

## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យការងារ និងវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានមុខងារ និងភារកិច្ច ជាអាទិ៍ដូចតទៅ ៖

*ក- វិស័យការងារ ៖*

- អនុវត្តច្បាប់ស្ដីពីការងារ សំដៅធានា កែលំអអនាម័យនិងសន្តិសុខការងារ សុខភាពកម្មករនិយោជិត និងល័ក្ខខ័ណ្ឌ ធ្វើការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន
- ធ្វើអធិការកិច្ចតាមសហគ្រាស គ្រឹះស្ថាន តាមការកំណត់នៃបទប្បញ្ញត្តិស្ដីពីរដ្ឋបាលការងារ
- តាមដានការអនុវត្តច្បាប់ស្ដីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងបទដ្ឋានការងារ ល័ក្ខខ័ណ្ឌការងារ អនាម័យ និងសន្តិសុខការងារ និងការការពារសុខភាពកម្មករនិយោជិត
- ជួយការពារ និងសម្របសម្រួលទំនាក់ទំនងរវាងបណ្ដាអង្គការតំណាងរបស់កម្មករនិយោជិត និងសមាគមនិយោជក និងបណ្ដាការងារនៃសេដ្ឋកិច្ចមិនរៀបរយ
- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការនានា ក្នុងតំបន់ និងលើសកលលោក ដើម្បី ជំរុញវិស័យការងារ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដំណើរការតាមនីតិវិធីនូវការដោះស្រាយវិវាទការងាររួម និងបុគ្គល
- គ្រប់គ្រងការងារប្រើប្រាស់ពលកម្មកម្ពុជាទាំងក្នុង និងក្រៅប្រទេស និងសហការក្នុងការគ្រប់គ្រងជនបរទេស ដែលចូលមកប្រកបមុខរបរនៅក្នុងប្រទេស
- សិក្សា និងរៀបចំគោលនយោបាយជាតិស្ដីពីការគ្រប់គ្រងមុខរបរ និងហត្ថពលកម្ម
- ដាក់ឱ្យអនុវត្តច្បាប់ស្ដីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់

2

**ស្តីពីការងារ និងជំរើសការបេឡាជាតិរបបសន្តិសុខសង្គម**

- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងពលកម្មកុមារ ។

***ខ- វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ៖***

- សិក្សា និងរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ ដើម្បីធ្វើការបូកសរុបសេចក្តីត្រូវការនៃទីផ្សារការងារ
- តាក់តែង និងអភិវឌ្ឍនយោបាយស្តីពីមុខរបរ ដោយឈរលើនយោបាយជាតិសម្រាប់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាក់តែង និងអភិវឌ្ឍគោលនយោបាយជាតិសម្រាប់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាក់តែងគោលការណ៍ និងគ្រប់គ្រងប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ពិនិត្យសំណើសុំបង្កើត ទទួលស្គាល់ គ្រឹះស្ថាន មជ្ឈមណ្ឌល ថ្នាក់រៀនអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ និងឯកជន
- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការនានា ក្នុងតំបន់ និងលើសកលលោក ដើម្បីជំរុញការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- សហការជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីពង្រឹង និងលើកកំពស់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- តាក់តែង និងអភិវឌ្ឍស្តង់ដារមុខរបរស្របតាមសេចក្តីត្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស
- រៀបចំ និងគ្រប់គ្រងការធ្វើតេស្តអំពីកិរិតវិជ្ជាជីវៈ គ្រប់ប្រភេទមុខរបរ និងធ្វើការផ្តល់ ឬដកហូតប័ណ្ណទទួលស្គាល់វិជ្ជាជីវៈ ដោយយោងតាមលទ្ធផលនៃការធ្វើតេស្ត
- គ្រប់គ្រងការងារហ្វឹកហ្វឺនកូនជាង និងបេឡានៃការហ្វឹកហ្វឺនកូនជាង តាមច្បាប់ស្តីពីការងារ ។

**មាត្រា ៤.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានរចនាសម្ព័ន្ធដូចតទៅ ៖

១- **ថ្នាក់កណ្តាល ៖**

**អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមមាន ៖**

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម
- នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ។

**អគ្គនាយកដ្ឋានការងាររួមមាន ៖**

- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានវិវាទការងារ
- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
- នាយកដ្ឋានសន្តិសុខសង្គម
- នាយកដ្ឋានការងារកុមារ
- នាយកដ្ឋានពេទ្យការងារ ។

**អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរួមមាន ៖**

- នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- នាយកដ្ឋានស្តង់ដាជាតិសមត្ថភាព
- នាយកដ្ឋានព័ត៌មានទីផ្សារការងារ ។

**អគ្គាធិការដ្ឋាន**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង**

**ខុទ្ទកាល័យរដ្ឋមន្ត្រី**

**២- អង្គភាពមូលដ្ឋាន**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- ការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្រុក ខ័ណ្ឌ ។

**៣- គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល**

អង្គការលេខរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣
## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៥.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ផែនការ ស្ថិតិ នីតិកម្ម និងសហប្រតិបត្តិការអន្តរជាតិ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាននាយកដ្ឋានចំនួន ០៤ ដូចបានចែងក្នុងមាត្រាខាងក្រោម ៖

**មាត្រា ៦.-**

**នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក**ទទួលបន្ទុក ៖

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានដោយសហការជាមួយអគ្គនាយកដ្ឋានដទៃទៀត ក្រោមឱវាទក្រសួង
- គ្រប់គ្រង និងចរាចររាល់ឯកសាររបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- ណែនាំរបៀបរបបធ្វើការងាររដ្ឋបាលដល់អង្គភាពក្រោមឱវាទក្រសួង
- ធ្វើរបាយការណ៍ការងារ និងកំណត់ហេតុផ្សេងៗ របស់ថ្នាក់ដឹកនាំក្រសួង
- គ្រប់គ្រងផ្នែករដ្ឋបាលចំពោះមន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាលពាក់ព័ន្ធបុគ្គលិករបស់ក្រសួង សម្រាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការ រៀបចំគោលនយោបាយ និងកម្មវិធីបណ្តុះបណ្តាលវិក្រឹត្យការមន្ត្រីរាជការក្នុងក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
- វាយតម្លៃ តម្លើងឋានៈ ឬលើកទឹកចិត្តដល់អង្គភាព ឬបុគ្គលដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំការងារបៀវត្សរ៍ពលកម្ម ប្រាក់កំរៃ និងរបបឧបត្ថម្ភគោលនយោបាយសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិកដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៧.-**

**នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម**ទទួលបន្ទុក ៖

- កសាងផែនការគោល និងសហការជាមួយផ្នែកជំនាញដែលពាក់ព័ន្ធរបស់ក្រសួង កសាងផែនការសកម្មភាពតាមបណ្តាផ្នែក
- សម្របសម្រួល រៀបចំកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេស ដោយសហការជាមួយផ្នែកជំនាញសហការជាមួយផ្នែកជំនាញនានា រៀបចំលិខិតស្នាម និងផែនការអភិវឌ្ឍន៍របស់ក្រសួង
- ប្រមូល និងរៀបចំស្ថិតិរបស់មុខសញ្ញាដែលក្រសួងទទួលបន្ទុក ។ រៀបចំ គ្រប់គ្រងទិន្នន័យ និងសិក្សាចំណោលស្ថិតិទាំងនោះ ក្នុងគោលដៅរៀបចំយុទ្ធសាស្ត្រ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាព និងទិសដៅអនាគតរបស់វិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យរបស់ក្រសួង
- ណែនាំរបៀបរបប និងធ្វើរបាយការណ៍សរុបអំពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ក្តាប់ និងប្រមូលសភាពការណ៍ជាក់ស្តែងពាក់ព័ន្ធវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពិនិត្យវាយតម្លៃបរិមាណ គុណភាពរបស់រដ្ឋបាល និងសមិទ្ធផលវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- សម្របសម្រួល និងពិនិត្យសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានារបស់ក្រសួង
- តាមដានការងារអនុវត្ត អនុសញ្ញា ច្បាប់ លិខិតបទដ្ឋាននានាទាក់ទងទៅនឹងការងាររបស់ក្រសួង
- ស្រាវជ្រាវ ដកស្រង់ ចងក្រងអត្ថបទច្បាប់ បទប្បញ្ញត្តិ សន្ធិសញ្ញានានាទាក់ទងទៅនឹងការងាររបស់ក្រសួង និងគ្រប់គ្រងឯកសារទាំងអស់នោះ
- ជាអ្នកជំនួយការច្បាប់ទាក់ទងទៅនឹងរាល់ការងារនីតិកម្មរបស់ក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៨.-**

**នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ**ទទួលបន្ទុក ៖

- រៀបចំគម្រោងថវិកាក្រសួង និងតាមដានវឌ្ឍនភាពការប្រតិបត្តិ
- គ្រប់គ្រងចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ បង់ចូលថវិការដ្ឋ
- គ្រប់គ្រង និងសម្របសម្រួលជំពូកថវិកា
- គ្រប់គ្រង និងពិនិត្យគណនីពិសេស
- គ្រប់គ្រង និងសម្របសម្រួលរាល់ចំណូល ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ
- សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការងារត្រួតពិនិត្យចំណូល ចំណាយរបស់ក្រសួង
- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានយន្តរបស់រដ្ឋ ដែលប្រគល់ឱ្យក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែក ប្រេងឥន្ធនៈ គ្រឿងបន្លាស់ និងជួសជុល ដាក់ជូនប្រធានស្ថាប័នពិនិត្យ និងសំរេច
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រងការប្រើប្រាស់ឧបករណ៍ព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៩.-**

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ** ទទួលបន្ទុក ៖

- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងការងារជាមួយផ្នែកជំនាញរបស់ក្រសួង ស្ថាប័ន អង្គការនានា និងបណ្តាប្រទេសក្នុងតំបន់ និងលើសកលលោក ដើម្បីអភិវឌ្ឍការងារគ្រប់វិស័យរបស់ក្រសួង ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំពិធីការ និងឯកសារនានាសម្រាប់ថ្នាក់ដឹកនាំក្រសួង ក្នុងការទទួលភ្ញៀវអន្តរជាតិ សម្រាប់កិច្ចប្រជុំ និងពិធីនានារបស់ក្រសួង
- រៀបចំអនុស្សរណៈ ឬកិច្ចព្រមព្រៀងរវាងក្រសួងជាមួយក្រសួង ស្ថាប័ន អង្គការនានា និងបណ្តាប្រទេសក្នុងតំបន់ និងលើសកលលោក និងតាមដានរាល់លទ្ធផលការងារអនុវត្ត ហើយរាយការណ៍ជូនថ្នាក់ដឹកនាំ
- តាមដាន និងបូកសរុបរាល់សកម្មភាពសហប្រតិបត្តិការអន្តរជាតិ និងអាស៊ានដែលក្រសួងបានចុះអនុស្សរណៈ ឬកិច្ចព្រមព្រៀង
- សម្រួលលិខិតស្នាម ដូចជា លិខិតឆ្លងដែន ទិដ្ឋាការរបស់មន្ត្រីរាជការក្រោមឱវាទក្រសួងដែលត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស តាមការចាត់តាំងរបស់ក្រសួង និងបណ្តាជនបរទេសដែលមកបំពេញការងារជាមួយក្រសួង
- សរុបសភាពការណ៍អន្តរជាតិ បទពិសោធន៍របស់បណ្តាប្រទេសក្នុងតំបន់ និងសកលលោក ហើយធ្វើការផ្សព្វផ្សាយព័ត៌មានដល់ផ្នែកជំនាញដែលពាក់ព័ន្ធ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយអង្គការ ស្ថាប័នជាតិ អន្តរជាតិ និងអាស៊ាន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៤

## អគ្គនាយកដ្ឋានការងារ

**មាត្រា ១០.-**

អគ្គនាយកដ្ឋានការងារទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងកិច្ចការអធិការកិច្ចការងារ វិវាទការងារ មុខរបរ និងហត្ថពលកម្ម សន្តិសុខសង្គម ការងារកុមារ និងពេទ្យការងារ ។

អគ្គនាយកដ្ឋានការងារដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានការងារមាននាយកដ្ឋានចំនួន ០៦ ដូចបានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ១១.-**

**នាយកដ្ឋានអធិការកិច្ចការងារ**ទទួលបន្ទុក ៖

- តាក់តែងបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌទូទៅនៃការងារ និងអនាម័យ

និងសន្តិសុខការងារ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានាស្តីពីការងារ ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌទូទៅនៃការងារ អនាម័យ និងសន្តិសុខការងារ សិទ្ធិការងារ
- ធ្វើការអប់រំ ផ្សព្វផ្សាយចំពោះនិយោជក និងកម្មករនិយោជិត ដើម្បីគោរពបទប្បញ្ញត្តិច្បាប់ស្តីពីការងារ
- ផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ចនូវករណីមិនប្រក្រតី និងការរំលោភផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យការងារ
- ផ្តល់យោបល់អំពីបញ្ហាទាក់ទងនឹងការរៀបចំ ឬកែប្រែសហគ្រាស គ្រឹះស្ថាន និងអង្គការចាត់តាំងដែលបានអនុញ្ញាតអំពីអាជ្ញាធររដ្ឋបាល ហើយដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌជីវភាពនៃកម្មករនិយោជិត និងគ្រួសារនៃជនទាំងនោះ
- ចាត់តាំង និងគ្រប់គ្រងភ្នាក់ងារចុះធ្វើអធិការកិច្ចការងារតាមសហគ្រាស គ្រឹះស្ថាន និងត្រួតពិនិត្យសកម្មភាពអធិការកិច្ចការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានអធិការកិច្ចការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១២.-**

**នាយកដ្ឋានវិវាទការងារ**ទទួលបន្ទុក ៖

- តាក់តែងបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោ-ជិត ក្នុងពេលប្រកបវិជ្ជាជីវៈរបស់ខ្លួន
- ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញាអន្តរជាតិនានាស្តីពីការងារ អំពីសិទ្ធិនៃការបង្កើតអង្គការវិជ្ជាជីវៈ
- ជួយការពារដល់បណ្តាអង្គការតំណាងរបស់កម្មករនិយោជិត និងនិយោជក នៅក្នុងសហគ្រាស គ្រឹះស្ថាន
- ដាក់ឱ្យដំណើរការនូវនីតិវិធីសម្រាប់ដោះស្រាយវិវាទការងារ
- ដោះស្រាយរាល់វិវាទការងារ
- តាមដាន និងជំរុញការចរចាជាសមូហភាព និងសំវាទសង្គម ព្រមទាំងពិនិត្យ និងចុះបញ្ជីការអង្គការវិជ្ជាជីវៈ និងអនុសញ្ញារួម ព្រមទាំងផ្តល់វិញ្ញាប័នប័ត្របញ្ជាក់ភាពជាតំណាងនៃអង្គការសហជីពកម្មករ
- ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានវិវាទការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។



**មាត្រា ១៣.-**

**នាយកដ្ឋានមុខរបរ និងហត្ថពលកម្មទទួលបន្ទុក ៖**

- សិក្សា និងលើកវិធានការសម្រាប់អភិវឌ្ឍន៍ និងការការពារមុខរបរ
- គ្រប់គ្រង ចេញប័ណ្ណការងារ សៀវភៅការងារ និងផ្តល់ទិដ្ឋាការការងារ ដល់កម្មករនិយោជិតខ្មែរដែលធ្វើការនៅក្នុង និងក្រៅប្រទេស
- ត្រួតពិនិត្យ និងផ្តល់ប័ណ្ណការងារ សៀវភៅការងារដល់ជនបរទេសដែលមកប្រកបមុខរបរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំក្របខ័ណ្ឌគតិយុត្តិពីវិធានការទាំងអស់ ដាក់ឱ្យអនុវត្តវិធានការ និងតាមដានការអនុវត្ត
- រៀបចំឱ្យមានការិយាល័យរកការងារធ្វើ នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- កសាងស្ថិតិមុខរបរ និងហត្ថពលកម្មក្នុង និងក្រៅប្រទេស ទៅតាមលំដាប់ថ្នាក់សកម្មភាពសេដ្ឋកិច្ច
- តាក់តែងបទប្បញ្ញត្តិ និងបទបញ្ជាស្តីពីការគ្រប់គ្រងជនបរទេស ដែលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស
- គ្រប់គ្រងជនបរទេសដែលមកប្រកបរបរក្នុងព្រះរាជាណាចក្រកម្ពុជា និងពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងករណីដែលមានពលករខ្មែរច្រើន អាចស្នើសុំបង្កើតអនុពន្ធការងារ
- ស្វែងរកទីផ្សារការងារជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានមុខរបរ និងហត្ថពលកម្មដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៤.-**

**នាយកដ្ឋានសន្តិសុខសង្គមទទួលបន្ទុក ៖**

**នាយកដ្ឋាន ផែនការ ស្ថិតិ និង សរុប** មានភារកិច្ច :

***ក-ផ្នែកផែនការ និង ស្ថិតិ*** :

- រៀបចំស្ថិតិរបស់មុខសញ្ញា ដែលក្រសួងទទួលបន្ទុក

- សិក្សា រៀបចំទិន្នន័យ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាពការងាររបស់ក្រសួង

- សហការជាមួយនាយកដ្ឋាននានា រៀបចំសេចក្តីណែនាំ សារាចរ លិខិតបទដ្ឋាននានា និងផែនការអភិវឌ្ឍរបស់ក្រសួង

- សហការរាល់ការងារបណ្តុះបណ្តាល និងការអភិវឌ្ឍមុខជំនាញ
- សិក្សាស្ថិតិ និង សិក្សាទិសដៅអនាគត ស្តីពីសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- គ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា និងបណ្ណាល័យរបស់ក្រសួង ។

*ខ-ផ្នែកសរុប :*

- ធ្វើរបាយការណ៍សរុបពីសកម្មភាព និងលទ្ធផលការងារប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ក្រសួង
- ពិនិត្យ វាយតម្លៃបរិមាណ គុណភាពរបស់រដ្ឋបាល និងសមិទ្ធផលសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ណែនាំរបៀបរបប និងគ្រប់គ្រងរបបរាយការណ៍ របស់អង្គភាពក្រោមឱវាទ និង ខេត្ត-ក្រុង
- ចុះតាមខេត្ត ក្រុង ដើម្បីក្តាប់ និងប្រមូលសភាពការណ៍ជាក់ស្តែងពីមុខសញ្ញា ដែលក្រសួងទទួលខុសត្រូវ
- ធ្វើរបាយការណ៍ការងារ និងកំណត់ហេតុផ្សេងៗ របស់ថ្នាក់ដឹកនាំក្រសួង
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងបានប្រគល់ជូន ។

នាយកដ្ឋាន ផែនការ ស្ថិតិ និងសរុប ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១១.-**

**នាយកដ្ឋាន ហិរញ្ញវត្ថុ និងផ្គត់ផ្គង់** មានភារកិច្ច :

***ក-ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ :***

- រៀបចំគម្រោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ
- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ បង់ចូលថវិការដ្ឋ
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា
- តាមដានវិលើកគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសម្របសម្រួលរាល់ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនី នៃការអនុវត្តលទ្ធកម្មសាធារណៈ
- សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការងារត្រួតពិនិត្យចំណូលចំណាយផ្សេង ៗ របស់ក្រសួង ។

***ខ-ផ្នែកផ្គត់ផ្គង់ :***

- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រង ចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និង ធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋ ដែលប្រគល់ឱ្យក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់

7

- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្ដាអង្គភាពខេត្ត-ក្រុងនានា
- កាន់បញ្ជីសលាកប័ត្រជាប្រចាំ និង គណនេយ្យរូបធាតុ
- រៀបចំប្រព័ន្ធព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេស នៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន ហិរញ្ញវត្ថុ និង ផ្គត់ផ្គង់ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១២.-**

**នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ** មានភារកិច្ច :

ក- ធ្វើការទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដើម្បីចូលរួមចំណែកអភិវឌ្ឍការងារគ្រប់វិស័យរបស់ក្រសួង

- រៀបចំពិធីការ សម្រាប់ថ្នាក់ដឹកនាំក្រសួងក្នុងការទទួលភ្ញៀវបរទេស កិច្ចប្រជុំនានា និងពិធីផ្សេងៗរបស់ក្រសួង
- រៀបចំអនុស្សរណៈរវាងក្រសួងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ អង្គការអន្តរជាតិ តាមដានលទ្ធផលនៃការងារអនុវត្ត រាយការណ៍ជូនថ្នាក់ដឹកនាំ ដើម្បីបង្កើនប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ
- គ្រប់គ្រង និងតាមដានសកម្មភាពបណ្ដាអង្គការនានា តាមកម្មវិធីអនុស្សារណៈជួយសម្រួលបែបបទផ្សេងៗរបស់អង្គការនានា ដែលសហការជាមួយក្រសួង ។

ខ- គ្រប់គ្រងការងារទាក់ទង សហប្រតិបត្តិការអន្តរជាតិ ដែលពាក់ព័ន្ធជាមួយវិស័យទាំងអស់ របស់ក្រសួង

- អនុវត្តការងារសហប្រតិបត្តិការរបស់ក្រសួង ក្នុងសហប្រតិបត្តិការអាស៊ាន និងអង្គការអន្តរជាតិផ្សេងៗទៀត ដោយមានកិច្ចសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- សម្រួលលិខិតស្នាម ដូចជាលិខិតឆ្លងដែន ទិដ្ឋាការ របស់មន្ត្រីរាជការក្រោមឱវាទក្រសួង ដែលត្រូវទៅបំពេញបេសកកម្មនៅក្រៅប្រទេស តាមការចាត់តាំងរបស់ក្រសួង
- សរុបសភាពការណ៍អន្តរជាតិ បទពិសោធរបស់បណ្ដាប្រទេសក្នុងតំបន់ និង សកលលោក ហើយធ្វើការផ្សព្វផ្សាយ ជូនព័ត៌មាននេះដល់អង្គភាព ដែលមានការពាក់ព័ន្ធ
- អនុវត្តភារកិច្ចផ្សេងៗ ទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការតាមការចាំបាច់ ។

## ជំពូក ទី ៧

## អគ្គនាយកដ្ឋានបច្ចេកទេស

**មាត្រា ១៣.-**

អគ្គនាយកដ្ឋានបច្ចេកទេស មានភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងលើការងារ ធ្វើទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងជំនាញកិច្ចការសុខុមាលភាពសង្គម សុខុមាលភាពកុមារ ស្តារលទ្ធភាពពលកម្ម យុវនីតិសម្បទា ការងារសោធននិវត្តន៍ សោធនបាត់បង់សមត្ថភាពការងារ មន្ត្រីរាជការស៊ីវិល និងយោធិន នៃកងយោធពលខេមរភូមិន្ទ គ្រប់គ្រង និងដោះស្រាយ ផ្តល់របបគោលនយោបាយជូនគ្រួសារ យោធិនពលី មរណៈ ជនពិការ និង បាត់ខ្លួន និង អភិវឌ្ឍសហគមន៍ ធ្វើឱ្យប្រសើរឡើង នូវលក្ខខណ្ឌជីវភាពរស់នៅរបស់អតីតយុទ្ធជន និងគ្រួសារ ។

អគ្គនាយកដ្ឋានបច្ចេកទេស ដឹកនាំដោយអគ្គនាយកមួយរូប និងមានអគ្គនាយករងមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**អគ្គនាយកដ្ឋាន បច្ចេកទេស** មាននាយកដ្ឋាន ៧ គឺ :

១. នាយកដ្ឋាន សុខុមាលភាពសង្គម

២. នាយកដ្ឋាន សុខុមាលភាពកុមារ

៣. នាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម

៤. នាយកដ្ឋាន យុវនីតិសម្បទា

៥. នាយកដ្ឋាន សោធននិវត្តន៍

៦. នាយកដ្ឋាន សោធនអតីតយុទ្ធជន

៧. នាយកដ្ឋាន អភិវឌ្ឍអតីតយុទ្ធជន

**មាត្រា ១៤.-**

**នាយកដ្ឋាន សុខុមាលភាពសង្គម** មានភារកិច្ច :

- កសាងគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធការងារសុខុមាលភាពសង្គម
- ជួយដល់ក្រុមជនដែលងាយរងគ្រោះ និងជួបការលំបាកជាងគេនៅក្នុងសង្គម ជាអាទិ៍ ជនអនាថា ស្រីពេស្យា ជនដែលត្រូវគេជួញដូរគ្រប់ប្រភេទ ជនដែលផ្ទុកមេរោគអេដស៍ (HIV/AIDs) ជនរស់នៅតាមចិញ្ចើមថ្នល់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធចាត់វិធានការផ្លូវច្បាប់ និងវិធានការក្នុងការត្រួតពិនិត្យ និងផែនការ កាត់បន្ថយជនអនាថា ទប់ស្កាត់អំពើពេស្យាចារ ការជួញដូរមនុស្ស និងការប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍
- សហការរៀបចំ ចាត់តាំងការប្រារព្ធទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា ជារៀងរាល់ឆ្នាំ
- រៀបចំ លក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុ និង សហការជាមួយក្រសួងពាក់ពន្ធ័ ក្នុងការផ្តល់មូលនិធិសម្បទាន សង្គមកិច្ច

-ជួយដល់ជនរងគ្រោះដោយមហន្តរាយផ្សេង ១ មានគ្រោះថ្នាក់ធម្មជាតិ សង្គ្រាម និង គ្រោះថ្នាក់ផ្សេង ១ ទៀត

-អនុវត្តភារកិច្ចផ្សេង ១ ទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន សុខុមាលភាពសង្គម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៥.-**

**នាយកដ្ឋាន សុខុមាលភាពកុមារ** មានភារកិច្ច :

- កសាងច្បាប់ បទប្បញ្ញត្តិនានាដែលមានការពាក់ព័ន្ធ នឹង សុខុមាលភាពកុមារ ច្បាប់ស្តីពីការសុំកូនក្នុងប្រទេស និង អន្តរប្រទេស...

-ដឹកនាំ គ្រប់គ្រង ការផ្តល់សេវា ថែទាំការពារដល់កុមារកំព្រា ទារកកំព្រា ដែលត្រូវគេបោះបង់ចោលនៅតាមមជ្ឈមណ្ឌលនានាទូទាំងប្រទេស

-បន្តកសាង និងពង្រីកបណ្តាញផ្តល់សេវាដល់កុមារ ដែលត្រូវការកិច្ចការពារពិសេសនៅតាមសហគមន៍

-ផ្តល់សេវាការពារទប់ស្កាត់ប្រឆាំងការកេងប្រវ័ញ្ចគ្រប់រូបភាពលើកុមារ មានជាអាទិ៍ : ពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ

-អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិ ដែលពាក់ព័ន្ធនឹងសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី

-បង្កើនកិច្ចសហការ ជាមួយដៃគូនានាទាំងស្ថាប័នរដ្ឋ អង្គការជាតិ អង្គការអន្តរជាតិពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល សំដៅលើកកម្ពស់ការផ្តល់សេវាដល់កុមារ

- សហការជាមួយស្ថាប័នពាក់ព័ន្ធរៀបចំទិវាកុមារអន្តរជាតិ ១ មិថុនា ជារៀងរាល់ឆ្នាំ

-ត្រួតពិនិត្យ វាយតម្លៃការអនុវត្ត គោលការណ៍ គម្រោងកម្មវិធី ទាំងផ្នែករដ្ឋ និងអង្គការជាដៃគូ ដែលធ្វើការងារសុខុមាលភាពកុមារ ។

នាយកដ្ឋាន សុខុមាលភាពកុមារ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និង មានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៦.-**

**នាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម** មានភារកិច្ច :

- គ្រប់គ្រងការងារស្តារលទ្ធភាពពលកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសង្គមជាតិនៃជនពិការ

- ផ្តល់ការព្យាបាលដោយចលនា ដល់ជនពិការគ្រប់ប្រភេទ

- គ្រប់គ្រងការផលិត និង ការបំពាក់ឧបករណ៍ទ្រទ្រង់រាងកាយ ដល់ជនពិការ

- អប់រំ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ជនពិការ

- ដោះស្រាយមុខរបរ និង អភិវឌ្ឍជីវភាពជនពិការតាមសហគមន៍
- រៀបចំតាក់តែង និងអនុវត្តគោលនយោបាយ ច្បាប់ ស្តីពីជនពិការ
- រៀបចំ និងចាត់ចែងសកម្មភាពវប្បធម៌ សិល្បៈ និង កីឡាជនពិការកម្ពុជា
- សហការរៀបចំ ចាត់តាំងប្រារព្ធទិវាជនពិការអន្តរជាតិ ៣ ធ្នូ និង ទិវាជនពិការផ្សេងទៀត ជារៀងរាល់ឆ្នាំ
- អនុវត្តភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន ស្តារលទ្ធភាពពលកម្ម ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៧.-**

**នាយកដ្ឋាន យុវនីតិសម្បទា** មានភារកិច្ច :

- កសាងគោលនយោបាយ ច្បាប់ បទប្បញ្ញត្តិ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងយុវនីតិសម្បទា
- សហការជាមួយស្ថាប័នពាក់ព័ន្ធ និងអង្គការដៃគូ រិះរកវិធានការអប់រំ ទប់ស្កាត់អំពើពាលា អនាថា អំពើទាស់ខុសនឹងច្បាប់ និងការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់ ដោយកុមារ យុវកុមារ
- រៀបចំបង្កើតមណ្ឌលថែទាំ អប់រំកុមារ យុវកុមារដែលមានអាយុក្រោម១៨ឆ្នាំនៅតាមភូមិភាគ ខេត្ត-ក្រុង ស្របទៅតាមអត្រាកំណើននៃអំពើពាលាអនាថា អំពើទាស់ខុសនឹងច្បាប់ និងការប្រើប្រាស់បំពានសារធាតុញៀនខុសច្បាប់
- ចូលរួម ការពារសិទ្ធិកុមារតាមផ្លូវច្បាប់
- សហការ ជាមួយក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ទណ្ឌិត នៅតាមពន្ធនាគារ
- សហការ ជាមួយស្ថាប័នពាក់ព័ន្ធ រិះរកវិធានការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងធ្វើ សមាហរណកម្ម ជនរងគ្រោះទាំងនោះទៅក្នុងសហគមន៍
- តាមដាន ត្រួតពិនិត្យ វាយតម្លៃ លើការអនុវត្តគោលការណ៍ គោលនយោបាយថ្នាក់ខេត្ត-ក្រុង លើការងារយុវនីតិសម្បទា
- អនុវត្តភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន យុវនីតិសម្បទា ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៨.-**

**នាយកដ្ឋាន សោធននិវត្តន៍** មានភារកិច្ច :

- កសាងគោលនយោបាយ ច្បាប់ និង បទប្បញ្ញត្តិនានា ពាក់ព័ន្ធទៅនឹងការអនុវត្តរបបសោធននិវត្តន៍ របបសោធនបាត់បង់សម្បទាវិជ្ជាជីវៈ និង របបគោលនយោបាយធានារ៉ាប់រងសង្គម ចំពោះមន្ត្រីរាជការស៊ីវិល
- រៀបចំតាក់តែងច្បាប់ស្តីពី បេឡាជាតិសោធន

- កសាងគោលនយោបាយ និង បទប្បញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធនឹងការបង្កើតសមាគមមនុស្សចាស់ ឬ សហគមន៍ ដើម្បីជួយទំនុកបំរុង ជនចាស់ជរា នៅមូលដ្ឋាន
- គ្រប់គ្រងរបបសោធននិវត្តន៍ និង សោធនបាត់បង់សម្បទាវិជ្ជាជីវៈ សម្រាប់មន្ត្រីរាជការតាមការកំណត់ នៃច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់គ្រងរបបគោលនយោបាយ ធានារ៉ាប់រងសង្គម សម្រាប់មន្ត្រីរាជការ ស៊ីវិល
- សហការជាមួយស្ថាប័នពាក់ពន្ធ័រៀបចំចាត់តាំងការប្រារព្ធទិវាមនុស្សចាស់ អន្តរជាតិ ០១ តុលា ជារៀងរាល់ឆ្នាំ
- តាមដាន ត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តគោលការណ៍ គោលនយោបាយ ស្តីពីរបបសោធននិវត្តន៍ សោធនបាត់បង់សម្បទាវិជ្ជាជីវៈ និង របបគោលនយោបាយធានារ៉ាប់រងសង្គម
- អនុវត្តភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋាន សោធននិវត្តន៍ ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ១៩.-**

**នាយកដ្ឋាន សោធនអតីតយុទ្ធជន** មានភារកិច្ច :

- សិក្សា និង រៀបចំរាល់អត្ថបទច្បាប់ និង បទប្បញ្ញត្តិ ដែលទាក់ទិន នឹង គោលនយោបាយអតីតយុទ្ធជន
- គ្រប់គ្រងការបើកផ្តល់ ប្រាក់ឧបត្ថម្ភគោលនយោបាយអតីតយុទ្ធជន
- រៀបចំផែនការ គ្រប់គ្រងស្ថិតិ និង រក្សាទុកបណ្ណសារអតីតយុទ្ធជន
- គ្រប់គ្រង និងដោះស្រាយរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ សម្រាប់យោធិន នៃកងយោធពលខេមរភូមិន្ទ តាមការកំណត់របស់ច្បាប់ ស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សមត្ថភាពការងារ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- គ្រប់គ្រង និងដោះស្រាយរបបគោលនយោបាយ ជូនជនពលី មរណៈ ពិការ បង្គូស្លាប់ បាត់ខ្លួន និងគ្រួសារ នៃកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងសេនាជន កងជីវពល ប្រជាពលរដ្ឋ ដែលបានបូជាជីវិត ដើម្បីប្រទេសជាតិ
- រៀបចំបង្កើតបេឡាជាតិ សោធនអតីតយុទ្ធជន
- អនុវត្តភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងបានប្រគល់ជូន ។

នាយកដ្ឋាន សោធនអតីតយុទ្ធជន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

**មាត្រា ២០.-**

**នាយកដ្ឋាន អភិវឌ្ឍអតីតយុទ្ធជន** មានភារកិច្ច :

- ជួយដល់អតីតយុទ្ធជន និងគ្រួសារ ក្នុងការអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ ស្វែងរកការងារ និង មុខរបរ
- ជួយអភិវឌ្ឍសហគមន៍ ក្នុងគោលដៅធ្វើឱ្យប្រសើរឡើង នូវលក្ខខណ្ឌជីវភាពរស់នៅ របស់អតីតយុទ្ធជន និង ក្រុមគ្រួសារ
- ចូលរួម ក្នុងការរៀបចំទិវាជាតិផ្សេង ៗ របស់អតីតយុទ្ធជន
- អនុវត្តភារកិច្ចផ្សេង ៗ ទៀត ដែលក្រសួងបានប្រគល់ជូន ។

នាយកដ្ឋាន អភិវឌ្ឍអតីតយុទ្ធជន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប និងមានអនុប្រធាននាយកដ្ឋានមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៨

## អង្គភាពមូលដ្ឋាន

### មាត្រា ២១.-

នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត ក្រុង ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង ។

នៅតាមស្រុក ខណ្ឌ មានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពរបស់ក្រសួង និងតាមបទបញ្ជារបស់មន្ទីរ ។

## ជំពូកទី ៩

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

### មាត្រា ២២.-

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមលក្ខខណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យ លេខ ៨១ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិកា ក្នុងបណ្តាក្រសួង ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

### មាត្រា ២៣.-

ការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ និងថ្នាក់ ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**មាត្រា ២៤.-**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងប្រធានស្ថាប័ន នៃស្ថាប័នដទៃទាំងនោះ ត្រូវសហការគ្នា ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៥.-**

អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និង បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០... មេសា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ២៦
- គ្រប់សាលាខេត្ត ក្រុង
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥
## អង្គការលេខក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៤៩ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាឱ្យដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអស់លោក លោកស្រី អ្នកជំនាញការជាន់ខ្ពស់អាល្លឺម៉ង់ និង អ៊ីតាលី ចំនួន ០៧ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងការជួយជំរុញឱ្យមានកំណែទម្រង់រដ្ឋបាលខេត្តបាត់ដំបង ដូចមាននាមខាងក្រោម :

១- លោកស្រី Rabea Brauer នាយិកាគម្រោងអាស៊ីទី ២ ( Project Director Asia Urbs II
២- លោក Dieter Gerhardt អ្នកជំនាញការជាន់ខ្ពស់ ខាងប្លង់គោល
៣-លោកបណ្ឌិត Carsten Burbank អ្នកជំនាញការជាន់ខ្ពស់ ខាងប្លង់គោល
៤- លោក Hans-Joerg Kolbeck អ្នកជំនាញការជាន់ខ្ពស់ខាងត្រួតពិនិត្យមើលកិច្ចការរដ្ឋបាលមូលដ្ឋា
៥- លោកស្រី Maria Trani អ្នកជំនាញការជាន់ខ្ពស់ខាងរចនាសម្ព័ន្ធនិងការចូលរួមរបស់ប្រជាពលរ
៦- លោកស្រី Sabrina Pocceschi អ្នកជំនាញការជាន់ខ្ពស់ខាងរចនាសម្ព័ន្ធនិងការចូលរួមរបស់ប្រជាពលរ
៧- លោក Lucio Caporizzi អ្នកជំនាញការជាន់ខ្ពស់ខាងរចនាសម្ព័ន្ធនិងការចូលរួមរបស់ប្រជាពលរ

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៤ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និងមាត្រា ២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៥០ អនក្រ - បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **អស្សឫទ្ធិ** ជូនអស់លោក លោកស្រី ជាដៃគូគំរោង ( Asia Urbs I អង្គការ DED និងអ្នកជំនាញការបរទេស ចំនួន ០៩ រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ បានចូលរួមយ៉ាងសកម្មក្នុងគំរោងកំណែទំរង់រដ្ឋបាល និង ឧបត្ថម្ភគាំទ្រការងារកសាងប្លង់គោល នៅស្រុកបាត់ដំបង ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោម :

១- លោក FRITHJOF KUHN អភិបាលស្រុកនិងជាប្រធានក្រុមប្រឹក្សាស្រុករ៉ែងស៊ិតនៃប្រទេសអាល្លឺម៉ង់

២- លោក MASSIMO BRUNINI អភិបាលក្រុងស្សូលេត្ត នៃ ប្រទេសអ៊ីតាលី

៣-លោកស្រី MONIKA SAVIER នាយិកាក្រុម BBJ ប្រចាំប្រទេសអ៊ីតាលី

៤- លោក HANS CLASEN អ្នកសំរបសំរួលគំរោងនគរូបនីយកម្មអាស៊ីប្រចាំស្រុករ៉ែងស៊ិតនៃប្រទេសអាល្លឺម៉ង់

៥- លោកស្រីANNARITA COSSO អ្នកសំរបសំរួលគំរោងនគរូបនីយកម្មអាស៊ីប្រចាំក្រុងស្សូលេត្តនៃប្រទេសអ៊ីតាលី

៦- កញ្ញា ELENA GRILLI អ្នកសំរបសំរួលគំរោងនគរូបនីយកម្មអាស៊ីប្រចាំក្រុម BBJ អ៊ីតាលី

៧- លោក WOLFGANG MEYER តំណាងមូលនិធិខុនរ៉ាដអាដិនណៅអ៊ែរ ប្រចាំប្រទេសកម្ពុជា
៨- លោក ECKHARD EMMEL នាយកអង្គការសេវាកម្មអភិវឌ្ឍន៍ អាល្លឺម៉ង់
៩- កញ្ញា BRITTA UHLIG ទីប្រឹក្សាប្លង់គោលស្រុកបាត់ដំបង

**មាត្រា ២ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យទទួលបានលទ្ធផលល្អ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ ០៣ ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៥១....អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

**សម្រេច**

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន១៣គ្រឿង ប្រគេន និង ជូន សប្បុរសជនចំនួន១៣រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាង ឧបដ្ឋានសាលា កុដិ ចេតិយ និងសមិទ្ធផលផ្សេងៗទៀត នៅក្នុងពុទ្ធសីមា វត្តឧណ្ណាលោមមុនី... 

**ក-មេដាយមាសស្ថាបនាជាតិ** :

-ព្រះមង្គលវិជ្ជាចារ្យ **សុខ ម៉ុនចឿន** លេខាអនុគណ ខណ្ឌមានជ័យ និងជាព្រះចៅអធិការវត្តឧទ្ទុមុនី បច្ច័យ ចំនួន ៤៣.៩៤៧ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ** :

| | | | |
|---|---|---|---|
| ១- ភិក្ខុ **សាត់ ប៉ូវ៉ាន់** | គ្រូសូត្រស្តាំ វត្តឧទ្ទុមុនី | បច្ច័យ | ៧.២៧៩ ដុល្លារ |
| ២- ភិក្ខុ **ឡាច ពុធ** | គ្រូសូត្រឆ្វេង វត្តឧទ្ទុមុនី | បច្ច័យ | ៧.៣៩០ ដុល្លារ |
| ៣- ភិក្ខុ **អ៊ុំ ឡុង** | វិន័យធរ វត្តឧទ្ទុមុនី | បច្ច័យ | ៦.៤៦៧ ដុល្លារ |
| ៤- ភិក្ខុ **គិន សារឿន** | លេខាធិការ វត្តឧទ្ទុមុនី | បច្ច័យ | ៦.១១៨ ដុល្លារ |

**គ-មេដាយសេរីវឌ្ឍស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឧបាសក **យូ ខ៊ីម** | សប្បុរសជន | ថវិកា ចំនួន ៣.១២៥ ដុល្លារ |
| ២-ឧបាសក **សុខ ម៉ែម** | សប្បុរសជន | ថវិកា ចំនួន ៣.០៥០ ដុល្លារ |
| ៣-ឧបាសក **ឈន់ គីមស៊ុយ** | សប្បុរសជន | ថវិកា ចំនួន ២.២៧៥ ដុល្លារ |
| ៤-ឧបាសក **ស្តើង ឈយន** | សប្បុរសជន | ថវិកា ចំនួន ២.១៥០ ដុល្លារ |
| ៥-ឧបាសិកា **នៅ ឡៃ** | សប្បុរសជន | ថវិកា ចំនួន ២.៩០៥ ដុល្លារ |
| ៦-ឧបាសិកា **អ៊ុំ ស៊ុមជុំ** | សប្បុរសជន | ថវិកា ចំនួន ២.៥១៣ ដុល្លារ |
| ៧-ឧបាសិកា **នៅ ចាន់ចំណាន** | សប្បុរសជន | ថវិកា ចំនួន ២.៤៧៨ ដុល្លារ |
| ៨-ឧបាសិកា **យិន មួយឡាង** | សប្បុរសជន | ថវិកា ចំនួន ២.៤៦៤ ដុល្លារ |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាង ព្រះវិហារ *វត្តនារាយណ៍* ក្នុងឃុំនារាយណ៍ ស្រុកឈូក ខេត្តកំពត ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **កែវ មុនី** ចៅអធិការវត្តនារាយណ៍ បច្ច័យ ចំនួន ២៣.២៥០ USD

២-លោក **យិន សិន** នៅប្រទេសអូស្ត្រាលី ថវិកា ចំនួន ១៦.៣៧០ USD

៣-លោក **ពយ ឡៀង** នៅប្រទេសអូស្ត្រាលី ថវិកា ចំនួន ១២.៣៨០ USD

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកស្រី **ពយ យឹន** នៅប្រទេសអូស្ត្រាលី ថវិកាចំនួន ៨.៧៣០ USD

២-ឧបាសិកា **ឆាន់ ធឿន** នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៧.៨៨៥ USD

៣-ឧបាសិកា **អ៊ុខ គីមគី** នៅក្រុងភ្នំពេញ ថវិកាចំនួន ៧.៥៦៧ USD

៤-ឧបាសក **ចិន ទសៅ** នៅក្រុងភ្នំពេញ ថវិកាចំនួន ៧.៨១៨ USD

**មាត្រា៣** ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.146-147

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៣៤៣ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៖០៖

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនមន្ត្រីរាជការ ក្រោមឱវាទរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :-

១-លោក **ខៀវ ចំនួមិ៉នឡើន** ប្រធាននាយកដ្ឋាន
២-លោក **ឆិន សុខឃួន** ប្រធាននាយកដ្ឋាន
៣-លោក **ជួប សុផាន** ប្រធាននាយកដ្ឋាន
៤-លោក **កែវ ឡុង** ប្រធាននាយកដ្ឋាន

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែ មករា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.153

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៣៧៥៤...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្តល់មេដាយការងារ

៚

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការក្រោមឱវាទ រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ចំនួន១៧រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ច បំរើជាតិមាតុភូមិ ដូចមាននាយនាមខាងក្រោម :-

**ក.មេដាយប្រាក់ការងារ :**

| | | |
|---|---|---|
| ១-លោក | **ឆាន់ ចន្ធី** | ប្រធានការិយាល័យ |
| ២-លោក | **ចាម ស៊ុនហេង** | ប្រធានការិយាល័យ |
| ៣-លោក | **ម៉ន គ្រីយ៉ា** | ប្រធានការិយាល័យ |

**ខ.មេដាយសំរិទ្ធការងារ :**

| | | |
|---|---|---|
| ១-លោកស្រី | **ម៉ុយ ជាលីន** | អនុប្រធានការិយាល័យ |
| ២-លោក | **ឡុន្ធី សុគន្ធារិទ្ធ** | អនុប្រធានការិយាល័យ |
| ៣-លោក | **ជិន ចន្ធថា** | អនុប្រធានការិយាល័យ |
| ៤-លោក | **ជា ប៊ុនរិទ្ធ** | អនុប្រធានការិយាល័យ |
| ៥-លោក | **ខៀវ សត្យា** | អនុប្រធានការិយាល័យ |
| ៦-លោក | **ហ៊ិន លក្ស្មី** | អនុប្រធានការិយាល័យ |
| ៧-លោកស្រី | **ពេជ សូរិយា** | អនុប្រធានការិយាល័យ |

| | | | |
|---|---|---|---|
| ៨-កញ្ញា | ស៊ិន | សុភាព | អនុប្រធានការិយាល័យ |
| ៩-លោក | ជ័យ | តុយ | អនុប្រធានការិយាល័យ |
| ១០-លោក | មាឃ | ស៊ីណាត | មន្ត្រី |
| ១១-លោកស្រី | នូ | ចាន់ធូ | មន្ត្រី |
| ១២-លោក | ម៉ែន | ណារិន្ទ | មន្ត្រី |
| ១៣-លោក | ឈុយ | សុភា | មន្ត្រី |
| ១៤-លោក | សុខ | ម៉ានិត | មន្ត្រី |

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ ០២ ឆ្នាំ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

B.154-155

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៛

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនមន្ត្រីនៃអង្គការ *JSC* ចំនួន០៣រូប ដែលបានផ្តល់ថវិកាសំរាប់ជួយ សាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ និង បង្គន់អនាម័យ ០១ខ្នង មាន០៣បន្ទប់ នៅសាលាបឋមសិក្សា កុយតឹប ក្នុងឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយនាម ខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-បងស្រី **ដឺ នីស** (*Sister DENISE*) ប្រធានអង្គការ *JSC* ឧបត្ថម្ភថវិកា ចំនួន ១១.២០០ ដុល្លារ

២-បងស្រី **អាត** (*Sister ATH*) មន្ត្រីសំរបសំរួលអង្គការ *JSC* ឧបត្ថម្ភថវិកាចំនួន ១០.៥០០ ដុល្លារ

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **ឡុង សុផល** មន្ត្រីជំនួយការអង្គការ *JSC* ឧបត្ថម្ភថវិកា ចំនួន ៣.២៧២ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យ នេះអោយទទួល បានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.161

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ចំនួន០៣រូប រស់នៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានជួយកសាង អគារសិក្សា០១ខ្នង មាន០៥បន្ទប់ និង បង្គន់អនាម័យ ០៣កន្លែង មាន០៨បន្ទប់ នៅ*វត្តអម្ពវន្នី* ឃុំតានី ស្រុកអង្គរជ័យ ខេត្តកំពត ដូចមានព្រះនាម និង នាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

- ឧបាសិកា **យ៉ាំ ស៊ីម** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.០០០ USD

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះតេជគុណ **វ័ន្ត ស្រីធុត្តា** គង់នៅ សហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

២-ឧបាសិកា **អ៊ុយ ម៉ាន** សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.០០០ USD

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.144

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៤៧ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសាកលវិទ្យាល័យជាតិគ្រប់គ្រង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៏ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល ។
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងមន្ត្រីចំនួន ១០ រូប នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ដូចមានរាយនាមខាងក្រោម ៖

១_លោក **ស៊ុំ ផល្លា** ជាព្រឹទ្ធបុរសមហាវិទ្យាល័យគ្រប់គ្រង
២_អ្នកស្រី **ស៊ឹម សុផិមារណី** ជាព្រឹទ្ធបុរសមហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច
៣_លោក **ជ័យ ផល់** ជាព្រឹទ្ធបុរសមហាវិទ្យាល័យទេសចរណ៍ និង បដិសណ្ឋារកិច្ច
៤_អ្នកស្រី **ទ៉ា បុណ្ណារ៉ា** ជាព្រឹទ្ធបុរសមហាវិទ្យាល័យហិរញ្ញវត្ថុ និង គណនេយ្យ
៥_លោក **នៅ សារ៉េត** ជាព្រឹទ្ធបុរសមហាវិទ្យាល័យនីតិសាស្ត្រ

៦_លោក **ចាយ ផាច** ជាព្រឹទ្ធបុរសមហាវិទ្យាល័យពតិមានវិទ្យា

៧_លោក **គីម វឌ្ឍិសិដ្ឋ** ជានាយកសាលាក្រោយឧត្តម

៨_លោក **ជា សឿន** ជានាយកសាខាសាកលវិទ្យាល័យជាតិគ្រប់គ្រងបាត់ដំបង

៩_លោក **សោ សុផាន់** ជានាយផ្នែកសិក្សាស្រាវជ្រាវ និង បណ្ណាល័យ

១០_លោក **ក្រូច សុផាន់ណា** ជានាយផ្នែករដ្ឋបាល បុគ្គលិក និង គណនេយ្យ

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងលោក **ញៀប ចាន់ណេ** ជាប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ...៣៥៩...អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០១ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ
- យោងតាមសំណើរបស់អគ្គលេខាធិការ នៃគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

### ស ម្រេ ច

**មាត្រា១** : ត្រូវបានតែងតាំង លោក **ឈន្ទ សម្បុគ** អោយបំពេញមុខងារជាប្រធានក្រុមពិធីការ និង បដិសណ្ឋារកិច្ច នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ០៤ ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ.

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៦០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការដាក់អោយមន្ត្រីរាជការចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល អោយចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពត៌មានវិទ្យា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានដាក់អោយលោក **ម៉ែន សារី** អនុមន្ត្រីថ្នាក់លេខ ១៤ អភិបាលស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចូលនិវត្តន៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៦១ អនក្រ.តត

# អនុក្រឹត្យ

**ស្តីពី**

**ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានផ្ទេរភារកិច្ចលោក **ឈឹម ចុនធី** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ៥ ពីអភិបាលស្រុកម៉ាឡៃ អោយមកជាអភិបាលស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

**មាត្រា ២ :** ត្រូវបានតែងតាំងលោក **ឆេត ឃុនណាល់** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១១ ជាអភិបាលស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ [illegible] ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
  *(ដើម្បីជូនជ្រាប)*
- *ដូចមាត្រា ៤ (ដើម្បីអនុវត្ត)*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៤២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ពាមនាជាតិ

*** 

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការ បង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ មេដាយស្ពាមនាជាតិ តាមលំដាប់ថ្នាក់ ប្រគេន និង ជូនព្រះសង្ឃ និង សប្បុរសជន ចំនួន ២៤រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា នៅវត្តខ័ណ្ឌសីមារាម រស្មីទួលអណ្តែត ក្នុងឃុំ ចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង ដូចមានរាយព្រះនាម និង នាមខាងក្រោម :-

**ក-មេដាយមាសស្ពាមនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | គង់ | ម៉ុនធឿន | បច្ច័យ ចំនួន ២៥.៥០០ ដុល្លារ |
| ២-លោក | ឌង់ | ទ៉ែម | ថវិកា ចំនួន ១៥.០០០ ដុល្លារ |
| ៣-លោកស្រី | ម៉ែន | អឿន | ថវិកា ចំនួន ១៦.០០០ ដុល្លារ |
| ៤-លោក | ឌែប | សុមិន | ថវិកា ចំនួន ១៣.០០០ ដុល្លារ |
| ៥-ឧត្តមសេនីយ៍ត្រី | ឈុំប | តេនា | ថវិកា ចំនួន ១២.៥០០ ដុល្លារ |
| ៦-លោកស្រី | ឌែប | សុខន | ថវិកា ចំនួន ១២.៣០០ ដុល្លារ |
| ៧-លោក | ស៊ិន | សារឿន | ថវិកា ចំនួន ១២.២០០ ដុល្លារ |
| ៨-លោក | អ៊ុក | ឃួច | ថវិកា ចំនួន ១២.១០០ ដុល្លារ |
| ៩-លោកស្រី | ឌុល | យឿប | ថវិកា ចំនួន ១២.០៥០ ដុល្លារ |
| ១០-លោក | ឌែន | ឌែម | ថវិកា ចំនួន ១១.០០០ ដុល្លារ |

| | | | |
|---|---|---|---|
| ១១-លោក | យូម | ឡៃ | ថវិកា ចំនួន ១០.៨០០ ដុល្លារ |
| ១២-លោក | ខែម | រិត | ថវិកា ចំនួន ១០.៦០០ ដុល្លារ |

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | យូប | ឃឿន | ថវិកា ចំនួន ៦.៥០០ ដុល្លារ |
| ២-អនុសេនីយ៍ឯក | មិន | សម្បូរ | ថវិកា ចំនួន ៦.១០០ ដុល្លារ |
| ៣-លោក | ឈិត | ឆាយ | ថវិកា ចំនួន ៥.៩០០ ដុល្លារ |
| ៤-លោក | យន់ | យឿង | ថវិកា ចំនួន ៥.៧០០ ដុល្លារ |
| ៥-លោក | ឈី | សែត | ថវិកា ចំនួន ៥.៤០០ ដុល្លារ |
| ៦-លោកស្រី | មុយ | ឡុង | ថវិកា ចំនួន ៥.២០០ ដុល្លារ |
| ៧-លោក | ឃឿម | សារ៉ែត | ថវិកា ចំនួន ៥.១៥០ ដុល្លារ |
| ៨-លោក | ហួត | យៅ | ថវិកា ចំនួន ៥.១០០ ដុល្លារ |

**គ_មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-លោក | នុំ | តើយ | ថវិកា ចំនួន ១.៤០០ ដុល្លារ |
| ២-លោក | រៀប | ខឿរ | ថវិកា ចំនួន ១.២០០ ដុល្លារ |
| ៣-លោក | ជិម | ម៉ែន | ថវិកា ចំនួន ១.២០០ ដុល្លារ |
| ៤-លោក | ឈិម | ឆាត | ថវិកា ចំនួន ១.១០០ ដុល្លារ |

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.154

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ :...៣៧៣...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការបង្កើតរាជាយស្វ័យយានកម្ពុជា ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

**ស ម្រេ ច**

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម **សុខុម គគចន្ទមុនី** ជាប្រធានអគ្គនាយក សហគ្រាសសាធារណៈរាជាយស្វ័យយានកម្ពុជា សំរាប់អាណត្តិទី ២ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ_កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :...៣២៤...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាភិបាល
# នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសាកលវិទ្យាល័យជាតិគ្រប់គ្រង ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១ :** តែងតាំងសមាជិកក្រុមប្រឹក្សាភិបាល នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១_ឯកឧត្តម | អ៊ុច ថុង | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង | ប្រធាន |
| ២_ឯកឧត្តម | គីម រិទ្ធិសិដ្ឋ | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣_លោក | ម៉ក់ ខយ | តំណាងក្រសួងអប់រំ យុវជន និង កីឡា | សមាជិក |
| ៤_លោក | ឌី សុខណ្ណា | តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៥_លោកស្រី | ម៉ាន់ ម៉ុនដេន | តំណាងបុគ្គលិក សាស្ត្រាចារ្យ សាកលវិទ្យាល័យជាតិគ្រប់គ្រង | សមាជិក |

**មាត្រា ២** : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៦៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលនានា ក្នុងវត្តសមាធិទ្រីយារាម ឃុំព្រះប្រសប់ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឧបាសិកា **ម៉េ ឃួចសុខនៀង** | សប្បុរសជននៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២៥.០០០ ដុល្លារ |
| ២-លោក **ម៉ៃ ឃុចាន់** | សប្បុរសជននៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ២០.៥០០ ដុល្លារ |
| ៣-អ្នកស្រី **ឈីន ជាម៉ា** | សប្បុរសជននៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ១២.៤៤៥ ដុល្លារ |
| ៤-ឧបាសិកា **ង្វួក ស៊ីមអ៊ឹម** | សប្បុរសជននៅសហរដ្ឋអាមេរិក | ទឹកប្រាក់ចំនួន ១០.២០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ឧបាសិកា **ឃួត ឆេងអៀង** | សប្បុរសជននៅឃុំព្រះប្រសប់ | ទឹកប្រាក់ចំនួន ៦.២៥០ ដុល្លារ |
| ២-ឧបាសក **មួយ ស្រ៊ុន** | សប្បុរសជននៅឃុំព្រះប្រសប់ | ទឹកប្រាក់ចំនួន ៥.១៨០ ដុល្លារ |
| ៣-លោក **ឡុង គុយ** | គណៈកម្មការវត្ត | ទឹកប្រាក់ចំនួន ៥.០៥០ ដុល្លារ |

**មាត្រា [illegible]:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ ដោយទទួលបាន លទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.157

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

## សម្រេច

**មាត្រា១** : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនទីប្រឹក្សា និង មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា ចំនួន០៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចជូនជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោមនេះ : -

**ក_មេដាយមាសការងារ :**

១-ឯកឧត្តម **អន ប៊ុណ្ណារឿន** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

២-ឯកឧត្តម **លឹម ឆខាយ** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

៣-ឯកឧត្តម **មាស ឆសារិទ្ធ** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា

៤-ឯកឧត្តម **ឯម សុនី** អគ្គនាយកទទួលបន្ទុកផ្នែកលេខាធិការ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

**ខ_មេដាយប្រាក់ការងារ :**

១-លោកស្រី **ដោក ចំនួនចំ** មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

២-លោកស្រី **ឌី សុខម៉ារ៉ា** មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

៣-កញ្ញា ចាំ សុភាព មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

៤-លោក ចាស់ ពណ្ណសំណាង មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

៥-លោកស្រី ឃឹម ផល្លី មន្ត្រីខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា

**មាត្រា២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណៈសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៥

**ហ៊ុន សែន**

**កន្លែងទទួល** :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B.119-120

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** :...៣២.៧...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តន៍ព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ស្តីពីការបង្កើតកំពង់ផែស្វយ័តក្រុងព្រះសីហនុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

**សំរេច**

**មាត្រា ១** : តែងតាំងលោក **លូ គឹមឈុន** ជាអគ្គនាយកកំពង់ផែស្វយ័តក្រុងព្រះសីហនុ សំរាប់អាណត្តិ ៣ ឆ្នាំបន្តទៀត ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន** :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៣៧៤៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតម្លើងឋានន្តរស័ក្តិនាយទាហានជាន់ខ្ពស់

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គមេបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

**សម្រេច**

**មាត្រា ១:** ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៤ រូប ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ១- វរសេនីយ៍ទោ | **ជា សុផាតក្សា** | អត្តលេខ | ២៣១៨៦២ |
| ២- វរសេនីយ៍ទោ | **ឈឿន កុសលចិរៈ** | អត្តលេខ | ០១២៩៩០ |
| ៣- វរសេនីយ៍ទោ | **យឹម សាត** | អត្តលេខ | ២៣១៧២៤ |
| ៤- វរសេនីយ៍ទោ | **យឹម សគុំណា** | អត្តលេខ | ២៣១៨៤៧ |

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា . ឆ្នាំ ២០០៥*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៦៥...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស /រកម/ ០៧០៤ /០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១.-**

តែងតាំង លោក **ឡាយ ឈាន** ជាជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ទទួលការងារកំណែទម្រង់រដ្ឋបាលមានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

**មាត្រា ២.-**

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធនឹងសាមីខ្លួន ដែលមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៥

ហ៊ុន សែន

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៧០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

ឈ១៣៩១៧

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា១:** ត្រូវបានតែងតាំងសមាជិកអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (ក.ប.ស) និងជំនួយការស្រាវជ្រាវអមសមាជិក ក.ប.ស ដូចមានរាយនាមខាងក្រោម:

១.លោក **ផាន់ ផល្លា** ជាសមាជិកផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

២.លោក **ឡាយ សុខឃៀង** ជាសមាជិកផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយនៃអគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

៣.លោក **ឈឹម សុគន្ធធារៈ** ជាសមាជិកផ្នែកផែនការ និង ទំនាក់ទំនងសាធារណៈនៃអគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

Conor Phaly

៤.លោកស្រី **ស្រស់ សុប្រាំផ្ការឈ្សាណលតិកា** ជាសមាជិកផ្នែកផែនការ និង ទំនាក់ទំនងសាធារណៈនៃ អគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

៥. លោក **ចា ដារ៉ា** ជាប្រធានផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

៦.លោក **កើត រិទ្ធ** ជាសមាជិកផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយនៃ អគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

៧.លោក **ស៊ូ សុជាតិ** ជាសមាជិកផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយនៃ អគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

៨.លោក **ហ៊ើល ចំរើន** ជាសមាជិកផ្នែកស្រាវជ្រាវ និង វិភាគគោលនយោបាយនៃ អគ្គលេខាធិការដ្ឋាន ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន

៩.លោក **ឈន សុភាព** ជាជំនួយការឯកឧត្តម **អូន ពន្ធមុនីរ័ត្ន** ប្រធាន ក.ប.ស មានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន

១០.លោក **ជូ ចណ្ណះ** ជាជំនួយការឯកឧត្តម **សុន គន្ធរ** អនុប្រធាន ក.ប.ស មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

១១.លោក **ឆេព ចណ្ណដា** ជាជំនួយការឯកឧត្តម **ហង់ជួន ណារ៉ុន** អគ្គលេខាធិការ ក.ប.ស មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

១២. លោក **កែន សម្បត្តិ** ជាជំនួយការឯកឧត្តម **ជូ ចិជិត្ត** សមាជិក ក.ប.ស មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៥

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

**ហ៊ុន សែន**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្ដីការគណៈរដ្ឋមន្ត្រី**

**លេខៈ** ១៩ សសរ.កបខ

## សេចក្ដីសម្រេច
## ស្ដីពីការកែសម្រួលលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា
## ទទួលបន្ទុកអនុម័តពាក្យច្បាប់

---

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
-បានឃើញអនុក្រឹត្យលេខ ៣៦/អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
-បានឃើញសេចក្ដីសម្រេចលេខ ២០ សសរ. ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា
-បានឃើញសេចក្ដីសម្រេចបន្ថែមលេខ ៣៣ សសរ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្ដីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា
-យោងតាមតម្រូវការចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១.-**

សេចក្ដីសម្រេចនេះជំនួសសេចក្ដីសម្រេចលេខ ២០ សសរ. ចុះថ្ងៃទី៣០ ខែ ឧសភា ឆ្នាំ២០០៣ និងលេខ ៣៣ សសរ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០០៣ ដែលត្រូវទុកជានិរាករណ៍។

**ប្រការ ២.–**

លេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ឡេង ប៉េងឡុង | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ | ប្រធាន |
| ២-ឯកឧត្តម ប៉ែន ដារ៉េត | ទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣-ឯកឧត្តម ក្រាញ់ ជ.តូនី | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៤-ឯកឧត្តម ផូវ សំភី | សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | អនុប្រធាន |
| ៥- លោក ហ៊ីង ធីឫទ្ធិ | ចៅក្រម | អនុប្រធាន |
| ៦-លោក សេង ស៊ីវុត្ថា | ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៧-ឯកឧត្តម ទូច សឹងហាយ | អគ្គលេខាធិការរងក.ប.ច. | អគ្គត្រួតពិនិត្យនិងបោះពុម្ព |
| ៨-លោក ថាច់ សែម | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ៩-លោក ស្រ៊ុន ធីរិទ្ធ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១០-លោក ស៊ា ម៉ៅ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១១-លោក អ៊ុត ស៊ីណាត | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១២-លោក ទេព សាបាន | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៣-លោក សូ ត្រៃ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការហិរញ្ញកិច្ច |
| ១៤-លោក យាង សេង | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៥-លោក ញ៉ែម សុភ័ក្រ្តា | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៦-លោក សំ រិទ្ធី | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៧-លោក កាន់ ណារិទ្ធ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការ |
| ១៨-លោក សែម ពីសី | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការកុំព្យូទ័រ |
| ១៩-លោក ទុំ ដារីដ | មន្ត្រីក្រុមប្រឹក្សាអ្នកច្បាប់ | ជំនួយការកុំព្យូទ័រ |
| ២០-លោកស្រី ឈួក សារុំ | មន្ត្រីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ | ជំនួយការកុំព្យូទ័រ |

ក្នុងករណីចាំបាច់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាចតែងតាំងជំនួយការបន្ថែមតាមសំណើរបស់ប្រធានលេខាធិការដ្ឋាន ។

**ប្រការ ៣.-**

លេខាធិការដ្ឋាន គណៈកម្មការបណ្ឌិតសភា អាចអញ្ជើញអ្នកឯកទេសមកពីក្រសួងផ្សេងៗ មានក្រសួងយុត្តិធម៌ គណៈមេធាវី និងមកពីមជ្ឈដ្ឋានផ្សេងៗព្រមទាំងអ្នកជំនាញការខ្មែរ និងបរទេសនានា មកប្រឹក្សាយោបល់ ។

**ប្រការ ៤.-**

លេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា មានភារកិច្ចដូចតទៅ :

១-ព្រាងបញ្ជីពាក្យ និងបកប្រែពាក្យបរទេសមកពាក្យខ្មែរ ពិនិត្យ និងសម្រេចដើម្បីកសាងសទ្ទានុក្រមពាក្យច្បាប់

២-បោះពុម្ពឯកសារសម្រាប់ដំណើរការ ការងាររបស់គណៈកម្មការបណ្ឌិតសភាទាំងមូល

៣-រៀបចំការប្រជុំរបស់គណៈកម្មការបណ្ឌិតសភា

៤-ធ្វើកំណត់ហេតុ និងរបាយការណ៍នៃអង្គប្រជុំ

៥-រៀបចំចងក្រង និងបោះពុម្ពពាក្យដែលអង្គប្រជុំបានអនុម័ត

៦-រៀបចំបោះពុម្ពសទ្ទានុក្រមពាក្យច្បាប់ និងរដ្ឋបាល ។

**ប្រការ ៥.-**

លេខាធិការដ្ឋានអនុវត្តការងារក្រោមការដឹកនាំរបស់ប្រធាន ។

**ប្រការ ៦.-**

សេចក្តីសម្រេចនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥

**ឧបនាយករដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៩៧ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការកំណត់សាធនភាពនៃក្រុមហ៊ុនធានារ៉ាប់រង

ឈឈឈ✱ឈឈឈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ១០៦/អនក្រ ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ២០០១ ណែនាំការអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង

-បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ.បក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញភាពចាំបាច់នៃការងារគ្រប់គ្រង ។

# សំរេច

**ប្រការ ១ :** និយមន័យដែលបញ្ចូលជាបច្ចេកសព្ទនៃប្រកាសនេះ ហើយត្រូវបានហៅថាជា«បច្ចេកស័ព្ទនិយមន័យ» គឺជាផ្នែកមួយនៃប្រកាសនេះ ។ និយមន័យទាំងនេះគឺជាខ្លឹមសារនៃពាក្យ និងឃ្លា និងជាឯកសារយោងដែលបានប្រើប្រាស់ ឬនឹងត្រូវបានប្រើប្រាស់នៅក្នុងប្រកាសនេះ ឬត្រូវប្រើប្រាស់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកែប្រែ ឬរៀបចំបន្ថែមលើតារាងនិយមន័យបច្ចេកស័ព្ទនេះបានគ្រប់ពេល ហើយត្រូវជូនដំណឹងនិងផ្តល់ការពិភាក្សាលើសំណើផ្លាស់ប្តូរប្រកបដោយហេតុផលសមស្រប ។

**ប្រការ ២ :** ពាក្យថា « ការធានារ៉ាប់រង » នៅក្នុងប្រកាសនេះគឺជាកិច្ចសន្យាធានារ៉ាប់រងមួយ ដែលអ្នកស្នើសុំអោយមានការធានារ៉ាប់រង ដូចដែលបានចុះកិច្ចសន្យាបង់បុព្វលាភធានារ៉ាប់រងទៅអោយក្រុមហ៊ុនធានារ៉ាប់រង ហើយក្រុមហ៊ុនធានារ៉ាប់រងនេះត្រូវទទួលខុសត្រូវធានាសំណងចំពោះការបាត់បង់ និងការខូចខាតទ្រព្យសម្បត្តិ ដែលបង្កដោយគ្រោះថ្នាក់ ឬនៅពេលដែលអ្នកទទួលការធានារ៉ាប់រងទទួលរងគ្រោះដោយរបួសស្នាមលើរាងកាយ មានពិការភាព ឬមានជំងឺ ។

**ប្រការ ៣ :** ការធានារ៉ាប់រងលើអចលនទ្រព្យ សំដៅការធានារ៉ាប់រងលើការខាតបង់ទ្រព្យសម្បត្តិ និងខូចខាតអចលនទ្រព្យ ការទទួលខុសត្រូវលើអចលនទ្រព្យ ការសាងសង់ ការតំឡើង ការដឹកជញ្ជូនផ្លូវគោក ផ្លូវអាកាស និង ផ្លូវទឹក ការធ្វើដំណើរ ការធានារ៉ាប់រងលើតួនាវា ការធានារ៉ាប់រងលើយន្តហោះ និងឥណទានពាណិជ្ជកម្ម ព្រមទាំងគ្រោះថ្នាក់ចំពោះឯកត្តជន ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចដំណើរការអាជីវកម្មធានារ៉ាប់រងបានតែក្នុងករណី នៃវិសាលភាពដែលមានចែងនៅក្នុងអាជ្ញាប័ណ្ណតែប៉ុណ្ណោះប្រសិនបើមាន និងដូចដែលបានឯកភាព ឬ ដោយបានបញ្ជាក់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតែប៉ុណ្ណោះតាមពេលវេលាជាក់ស្តែង លើកលែងតែការធានារ៉ាប់រងលើគ្រោះថ្នាក់ និងលើគ្រោះថ្នាក់ការងារ ដែលក្រុមហ៊ុនធានារ៉ាប់រងទាំងអស់អាចដំណើរការកិច្ចប្រតិបត្តិការដូចគ្នា ។

**ប្រការ ៤ :** ប្រកាសនេះអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬ ក្រុមហ៊ុនធានារ៉ាប់រងមិនមែនជីវិត និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ឬសាខានៃក្រុមហ៊ុនធានារ៉ាប់រងបរទេស និងក្រុមហ៊ុនធានារ៉ាប់រងបន្តបរទេស ដែលបានទទួលសិទ្ធិស្របច្បាប់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនគិតអំពីកម្មសិទ្ធិភាព

ឡើយ ។ ការធ្វើអាជីវកម្មដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការមិនគោរពតាមច្បាប់ស្តីពី ការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងការមិនអនុវត្តតាមប្រកាសនេះ ព្រមទាំងសេចក្តីណែនាំ ឬកិច្ចព្រមព្រៀងពាក់ព័ន្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអំពើខុសច្បាប់ ។

ប្រការ ៥ : សេចក្តីណែនាំស្តីពី ទំរង់ និងខ្លឹមសារនៃ របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីណែនាំលើបញ្ហាបច្ចេកទេសផ្សេងៗ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងចេញតាមការចាំបាច់ និងតាមពេលវេលាជាក់ស្តែង ។ ការមិនគោរពតាមប្រកាសនេះ ឬមិនគោរពច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង សេចក្តីណែនាំ ឬកិច្ចព្រមព្រៀងដទៃទៀត ដែលបានឯកភាពជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺអំពើខុសច្បាប់ ។

## ការផ្តល់អាជ្ញាប័ណ្ណ

ប្រការ ៦ : មុនពេលចាប់ផ្តើមធ្វើអាជីវកម្មធានារ៉ាប់រង ក្រុមហ៊ុនដែលបានដាក់ពាក្យសុំអាជ្ញាប័ណ្ណធានារ៉ាប់រង ត្រូវបំពេញនូវលក្ខខណ្ឌរបស់ច្បាប់ អនុក្រឹត្យ និងច្បាប់ដទៃទៀត ព្រមទាំងលក្ខខណ្ឌបន្ថែម ឬសេចក្តីណែនាំដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមពេលវេលាជាក់ស្តែង ។

ប្រការ ៧ : ក្រុមហ៊ុនធានារ៉ាប់រងនីមួយៗ ត្រូវដាក់ពាក្យមកកាន់ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទទួលអាជ្ញាប័ណ្ណសំរាប់ដំណើរការអាជីវកម្មធានារ៉ាប់រងនៅព្រះរាជាណាចក្រកម្ពុជា ។ នៅពេលដាក់ពាក្យស្នើសុំ អ្នកស្នើសុំត្រូវផ្តល់ឯកសារទាំងឡាយដែលបញ្ជាក់ថា អ្នកស្នើសុំបានបំពេញតាមលក្ខខណ្ឌនៃសាធនភាពគ្រប់គ្រាន់ តាមការកំណត់នៅក្នុងប្រកាសនេះ ។

អាជ្ញាប័ណ្ណធានារ៉ាប់រងគឺមានសុពលភាពរយៈពេល ៥ ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណ ហើយអាចបន្តបានរយៈពេល ៣ ឆ្នាំម្តង ។ ការបន្តអាជ្ញាប័ណ្ណត្រូវដាក់ពាក្យសុំបន្តអាជ្ញាប័ណ្ណអោយបានយ៉ាងតិចណាស់ ៣ ខែ មុនពេលអាជ្ញាប័ណ្ណអស់សុពលភាព ។ ការបន្តអាជ្ញាប័ណ្ណគឺពឹងផ្អែកលើការគោរពទៅតាមលក្ខខណ្ឌដូចដែលបានចែងនៅក្នុងច្បាប់ អនុក្រឹត្យ

ប្រកាស សារាចរណែនាំ ឬការតម្រូវផ្សេងៗ ឬការណែនាំពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជារៀងរាល់ពេល ។

**សាធនភាព**

**ប្រការ ៨ :** ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវមានប្រាក់គ្រប់គ្រាន់សំរាប់សាធនភាព ។ ចំពោះអាជីវកម្មធានារ៉ាប់រងទូទៅ ប្រាក់សាធនភាពមិនត្រូវតិចជាងទឹកប្រាក់អតិបរិមានៃ ÷

ក. ១.៥០០.០០០ ដុល្លារអាមេរិក (មួយលានប្រាំរយពាន់) ។ ចំនួនប្រាក់សាធនភាពនេះ រួមបញ្ចូលទាំងប្រាក់តំកល់នៅធនាគារជាតិនៃកម្ពុជាចំនួន ៧០០.០០០ ដុល្លារអាមេរិក (ប្រាំពីររយពាន់) ដែលអាចជាសាច់ប្រាក់សុទ្ធ ឬជាមូលបត្ររដ្ឋដែលមានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ

ខ. ៣០%នៃចំណូលបុព្វលាភសុទ្ធនៅរបាយការណ៍ហិរញ្ញវត្ថុសំរាប់ឆ្នាំចុងក្រោយ ។

កំរិតប្រាក់សាធនភាពនេះ ត្រូវជ្រើសរើសយកស្ទួចនាករណាដែលខ្ពស់ជាងក្នុងចំណោម «ក» និង «ខ»។

គ. ជារៀងរាល់ពេល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងកំណត់មូលដ្ឋាននៃការគណនាសាធនភាពចំពោះក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្ត និងបរិមាណទ្រព្យសកម្ម ប្រភេទនៃទ្រព្យសកម្ម និងទីកន្លែងរបស់ទ្រព្យសកម្ម ដែលគាំទ្រសាធនភាព និងប្រាក់បំរុងបច្ចេកទេស ។ ប្រាក់បំរុងបច្ចេកទេសមានន័យថា បរិមាណទឹកប្រាក់ដែលបានមកពីការប្រើប្រាស់វិធីសាស្ត្រវាយតំលៃ ដែលអាចទទួលយកបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះសំណងទាមទារមិនទាន់ទូទាត់ និងបុព្វលាភមិនទាន់ចាត់ជាចំណូលសុទ្ធនៃការធានារ៉ាប់រងបន្ត (រួមមានសមាមាត្រ និងមិនមែនសមាមាត្រ)។

ឃ. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងជូនដំណឹងអោយបានគ្រប់គ្រាន់អំពីសំណើផ្លាស់ប្តូរណាមួយ និងបញ្ជាក់ពីកាលបរិច្ឆេទក្នុងការអនុវត្តន៍ ។

ង. តាមរយៈសេចក្តីណែនាំ និងសេចក្តីជូនដំណឹង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបញ្ជាក់នូវទុនសាធនភាពដែលតំរូវអោយមានសំរាប់ក្រុមហ៊ុនណាមួយ ដោយមិនតិចជាងចំនួនដែលបានចែងខាងលើឡើយ ។

ច. ដំណើរការអាជីវកម្មដោយពុំមានប្រាក់សាធនភាពគ្រប់គ្រាន់តាមការកំណត់ ហើយការមិនគោរពតាមប្រកាសនេះ ឬមិនគោរពច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង ក៏ដូចជាសេចក្តីសំរេច ឬកិច្ចព្រមព្រៀងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គឺអំពើខុសច្បាប់ ។

ប្រការ ៩ : ទាក់ទងនឹងប្រាក់ចំណេញរបស់ក្រុមហ៊ុនធានារ៉ាប់រងមួយ មិនត្រូវបានអនុញ្ញាតអោយបែងចែកភាគលាភទៅកាន់ភាគទុនិករបស់ខ្លួនឡើយ លុះត្រាតែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ព្រមជាលាយល័ក្ខអក្សរថាក្រុមហ៊ុនបានឆ្លើយតប ហើយអាចបន្តឆ្លើយតបនឹងកាតព្វកិច្ចសាធនភាពនៅក្នុងពេលខាងមុខដ៏ខ្លី ។ ការបើកប្រាក់ភាគលាភ ឬចំណូលទុនអាចដំណើរការទៅបានប្រសិនបើមានការឯកភាពជាលាយល័ក្ខអក្សរពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប៉ុណ្ណោះ ។

## ការធានារ៉ាប់រងបន្ត

ប្រការ ១០ : ការរៀបចំក្នុងការធានារ៉ាប់រងបន្តចេញទៅក្រៅប្រទេសទាំងអស់ ចាំបាច់ត្រូវតែដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រចាំឆ្នាំ ។ ក្នុងរវាង ៣ ខែដើមឆ្នាំ ដែលការរៀបចំចាត់ចែងទាំងនោះត្រូវអនុវត្ត និងត្រូវផ្លាស់ប្តូរ កាត់បន្ថយឬបង្កើនឡើង ទៅតាមការណែនាំរបស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ របាយការណ៍ពាក់ព័ន្ធនឹងការធានារ៉ាប់រងបន្តទៅក្រៅដែលបានធ្វើសវនកម្មហើយត្រូវផ្ញើអោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរវាង ៣ ខែដើមឆ្នាំនីមួយៗ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចណែនាំអោយធ្វើរបាយការណ៍តាមគំរូដែលបានកំរូវ ។

ប្រការ ១១ : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ឬ ក្រុមហ៊ុនធានារ៉ាប់រងមិនមែនអាយុជីវិតទាំងអស់ ត្រូវធានារ៉ាប់រងបន្តរហូតដល់ម្ភៃភាគរយ (២០%) នៃសេវាធានារ៉ាប់រងដែលបានចុះកិច្ចសន្យា (ចំនួនអតិបរមា និងត្រូវបញ្ជាក់នៅក្នុងកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនដែលទទួលយក និង ក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋ) ជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រងបន្តរបស់រដ្ឋ ។

## ទ្រព្យសកម្ម

ប្រការ ១២ : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្តទាំងអស់ដែលបានទទួលអាជ្ញាប័ណ្ណ ដើម្បីប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវប្រើប្រាស់មូលធនបច្ចុប្បន្នរបស់ខ្លួន និងមូលនិធិបំរុងបច្ចេកទេសរបស់ខ្លួននៅក្នុងទ្រព្យសកម្ម ដូចដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំណត់តាមពេលវេលាជាក់ស្តែង ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអាចកំណត់នូវបរិមាណ និងសមាមាត្រនៃមូលធនបច្ចុប្បន្នដែលមាននៅក្នុងទ្រព្យសកម្មណាមួយ ។

## ការដោះស្រាយបណ្តឹងទាមទារសំណង

**ប្រការ ១៣** : វិធីសាស្ត្រនៃការដោះស្រាយបណ្តឹងទាមទារសំណង ជាដំបូងត្រូវមានមូលដ្ឋានផ្អែកទៅលើការចរចារដោយសន្តិវិធី និងសម្រុះសម្រួលរវាងក្រុមហ៊ុនធានារ៉ាប់រង និងអ្នកទទួលការធានារ៉ាប់រង ឬតតិយភាគីដែលជាភាគីរងគ្រោះ ។ ប្រសិនបើការសម្រុះសម្រួលមិនទទួលជោគជ័យ ពាក្យបណ្តឹងនេះនឹងត្រូវបញ្ជូនទៅអោយមជ្ឈត្តករសំរាប់ធ្វើការដោះស្រាយ ។ ដើម្បីចាត់ការនៅក្នុងការដោះស្រាយសំណង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានកិច្ចព្រមព្រៀងពីអ្នកទទួលការធានារ៉ាប់រង និងពីក្រុមហ៊ុនធានារ៉ាប់រង អាចតែងតាំងមជ្ឈត្តករ ឬបង្កើតគណៈកម្មការមជ្ឈត្តករសំរាប់កំណត់វិវាទ ។ នៅក្នុងករណីដែលភាគីទាំងពីរនៅមិនទាន់ឯកភាពគ្នា ភាគីដែលមិនយល់ព្រមអាចនឹងប្តឹងទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

## នាយកគណៈកម្មាធិការប្រតិបត្តិ និង ក្រុមប្រឹក្សា

**ប្រការ ១៤** : នៅក្នុងករណីដែលក្រុមហ៊ុនធានារ៉ាប់រងមួយមានបំណងចង់ផ្លាស់ប្តូរប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយករបស់ខ្លួន ក្រុមហ៊ុននោះត្រូវរាយការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យទៅលើលក្ខណៈសម្បត្តិចំពោះបុគ្គលដែលត្រូវមកកាន់មុខតំណែងនេះ ។ ប្រធានក្រុមប្រឹក្សាភិបាល ឬអគ្គនាយកណាក៏ដោយចាំបាច់ត្រូវមានបទពិសោធន៍ និងជំនាញសមស្របហើយត្រូវបំពេញលក្ខណៈវិនិច្ឆ័យ «សមស្រប» ដូចដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមពេលវេលាជាក់ស្តែង ហើយបុគ្គលនោះត្រូវតែទទួលការឯកភាពពី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិនមុននឹងធ្វើការតែងតាំង ។

**ប្រការ ១៥** : ប្រធានក្រុមប្រឹក្សាភិបាល អគ្គនាយក នាយក និងប្រធានគណៈកម្មាធិការប្រតិបត្តិ ឬបេក្ខភាពប្រធានក្រុមប្រឹក្សាភិបាល បេក្ខភាពនាយក បេក្ខភាពអគ្គនាយក ឬបេក្ខភាពប្រធានគណៈកម្មាធិការប្រតិបត្តិចាំបាច់ត្រូវមានបទពិសោធន៍ និងជំនាញព្រមទាំងបំពេញនូវលក្ខណៈវិនិច្ឆ័យ «សមស្រប» ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមពេលវេលាជាក់ស្តែង ។ បេក្ខជនសំរាប់ធ្វើការតែងតាំង ចាំបាច់ត្រូវតែទទួលការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុនសិនមុននឹងធ្វើការតែងតាំង ។

**ប្រការ ១៦** : បុគ្គលដែលកាន់មុខតំណែងជា នាយក ប្រធាននាយកប្រតិបត្តិ ឬ នាយកចាត់ការ ត្រូវតែជា «បុគ្គលល្អ និងត្រឹមត្រូវ» ហើយមានលក្ខណៈសម្បត្តិដូចខាងក្រោម÷

គ. មានភាពសុចរិតទៀងត្រង់ មានសមត្ថភាព និងលក្ខណៈវិនិច្ឆ័យសមស្របសំរាប់បំពេញនូវភារកិច្ច នៃមុខតំណែងនោះ ។

ខ. បំពេញការងារដោយយកចិត្តទុកដាក់ និងមានភាពទទួលខុសត្រូវខ្ពស់ និងបំពេញលក្ខណៈវិនិច្ឆ័យផ្សេងទៀត ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ១៧** : បុគ្គលដែលត្រូវទទួលតំណែងជាប្រធាននាយកប្រតិបត្តិ ឬ នាយកចាត់ការត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម ÷

ក. ត្រូវមានកម្រិតវប្បធម៌ខ្ពស់ និងមានបទពិសោធន៍ ដែលអាចអនុញ្ញាតអោយសាមីខ្លួនបំពេញតួនាទីបានសមស្របនូវភារកិច្ចរបស់ខ្លួន ។

ខ. មិនត្រូវមានមុខតំណែងនៃការទទួលខុសត្រូវក្នុងគណៈកម្មាធិការគ្រប់គ្រង របស់ក្រុមហ៊ុនណាមួយដែលត្រូវបានចោទប្រកាន់អំពីបទល្មើសនៅក្រោមច្បាប់ណាមួយនៅក្នុងអំឡុងពេល ឬអាណត្តិការងាររបស់ខ្លួន លើកលែងតែមានបុគ្គលមានសមត្ថកិច្ចណាមួយបញ្ជាក់ថា ការរំលោភនោះបានប្រព្រឹត្តទៅដោយខ្លួនពុំបានដឹង ឬ ខ្លួនពុំបានឯកភាព ហើយសាមីជនពុំឋិតនៅក្នុងមុខតំណែងបង្កបទល្មើសនោះទេ ។

គ. មិនត្រូវមានមុខតំណែងនៃការទទួលខុសត្រូវ ក្នុងគណៈកម្មាធិការគ្រប់គ្រងនៃក្រុមហ៊ុនណាមួយដែលនៅក្នុងអំឡុងអាណត្តិធ្វើការងាររបស់ខ្លួន÷

១. មិនបានទូទាត់ប្រាក់ពិន័យតាមការទាមទារ ។

២. បានពន្យាពេលការទូទាត់ ឬ បានបង្កើននូវប្រាក់ជំពាក់ឥណទាយករបស់ខ្លួន ឬ

៣. ធ្លាប់មានគេតែងតាំងនាយកគ្រប់គ្រងលើទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននោះ ។

ឃ. ត្រូវមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើការងារពេញម៉ោង ហើយមិនអាចធ្វើអាជីវកម្មណាផ្សេងទៀត ឬបំពេញមុខវិជ្ជាជីវៈនៅក្នុងប្រទេសកម្ពុជា លើកលែងតែធ្វើជានាយកពុំមែនប្រតិបត្តិ ឬជាភាគទុនិករបស់ក្រុមហ៊ុនមួយទៀត ។

ង. មិនត្រូវពាក់ព័ន្ធជាមួយនឹងសកម្មភាពនយោបាយឡើយ ។

ច. មិនត្រូវបង្កអោយមានទំនាស់ផលប្រយោជន៍ជាមួយនឹងក្រុមហ៊ុន ទោះបីជាតាមរយៈសាមីខ្លួនឯង ឬ តាមរយៈប្តីប្រពន្ធកូនឪពុកម្តាយ ឬបងប្អូនរបស់ខ្លួនឡើយ ។

ជ. មិនត្រូវធ្វើសកម្មភាពតាមបែបណាមួយ ដែលបង្កអោយមានមន្ទិលសង្ស័យទៅលើសមត្ថភាពរបស់ខ្លួន នៅក្នុងការកាន់មុខតំណែងជាប្រធាននាយកប្រតិបត្តិ ឬនាយកចាត់ការ ឬធ្វើសកម្មភាពយ៉ាងចំហរ ដោយផ្ទុយនឹងក្រមសីលធម៌វិជ្ជាជីវៈ ជាពិសេសក្នុងការចាត់ការជាមួយម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រង អ្នកទាមទារសំណង និងជាមួយអតិថិជន ។

ឈ. មិនត្រូវជាភាគីមួយ ចំពោះសកម្មភាពណាមួយ ឬ សេចក្តីសំរេចណាមួយ នៃគណៈគ្រប់គ្រងរបស់ក្រុមហ៊ុនដែលប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ក្រុមហ៊ុនធានារ៉ាប់រង ដែលបានទទួលអាជ្ញាប័ណ្ណ និងម្ចាស់ប័ណ្ណសន្យាធានារ៉ាប់រងរបស់ខ្លួន ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិពេញលេញក្នុងការកំណត់ថាតើបុគ្គលណាម្នាក់បានអនុវត្តតាមលក្ខខណ្ឌវិនិច្ឆ័យនេះ ។

## ភាតព្វកិច្ចផ្នែកហិរញ្ញវត្ថុ និង ស្ថិតិ

**ប្រការ ១៨** : នៅក្នុងរយៈពេលប្រាំមួយ (៦)ខែ ដោយគិតចាប់ពីចុងការិយបរិច្ឆេទនីមួយៗ ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្តត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច ក៏ដូចជាឯកសារចាំបាច់ដទៃទៀតរបស់ក្រុមហ៊ុនដែលទើបបានបញ្ចប់ទៅថ្មីៗរួមមានឯកសារទាំងឡាយណា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតំរូវអោយ ។

**ប្រការ ១៩** : ក្រុមហ៊ុនធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ត្រូវរៀបចំស្ថិតិអាជីវកម្ម និងខ្លឹមសារសង្ខេបប្រចាំខែ ហើយផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមានពត៌មានដែលមានចែងនៅក្នុងច្បាប់ ព្រមទាំងពត៌មានដទៃទៀតដែលតំរូវដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដូចដែលបានចែងនៅក្នុងអាទិភាពដែលបានយល់ព្រមក្នុងគំរូរបាយការណ៍ ។

**ប្រការ ២០** : របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រងបន្តដែលមានអាជ្ញាប័ណ្ណត្រូវបានគេបង្កើតឡើងដោយប្រើប្រាស់នូវស្តង់ដារគណនេយ្យទូទៅ ដែលបានទទួលស្គាល់ដោយកម្ពុជា ដូចដែលបានចែងនៅក្នុងប្រកាស ឬកែប្រែដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមពេលវេលាជាក់ស្តែង ឬបានអនុម័តដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ២១** : របាយការណ៍ហិរញ្ញវត្ថុរបស់អ្នកធានារ៉ាប់រង និងអ្នកធានារ៉ាប់រងបន្តដែលមានអាជ្ញាប័ណ្ណត្រូវតែសំរួលនូវមូលនិធិ ចំពោះអ្នកមានភាគហ៊ុនដើម្បីកំណត់សាធនភាព ដោយប្រើប្រាស់វិធីសាស្ត្រដែលអាចទទួលយកបានសំរាប់ការគណនាបុព្វលាភដែលមិនទាន់ទទួលបាន (ឬហានិភ័យដែលមិនទាន់ហួសកំណត់) និងការទាមទារអោយសងប្រាក់ធានារ៉ាប់រងដូចដែលបានចែងនៅក្នុងតំរោងនិយមន័យ ។

**ប្រការ ២២** : របាយការណ៍ហិរញ្ញវត្ថុត្រូវតែសំរួលតាមមូលនិធិអ្នកមានភាគហ៊ុនដើម្បីកំណត់សាធនភាព ដោយធ្វើការវាយតំលៃទ្រព្យសកម្ម ឬដកទ្រព្យសកម្មចេញដូចដែលបានចែងនៅក្នុងតំរោងនៃតំរូគណនេយ្យ ដោយយោងតាមទ្រព្យសកម្ម និងដោយពឹងផ្អែកលើការផ្លាស់ប្តូរ ឬកែប្រែជាប្រចាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសំរាប់អ្នកធានារ៉ាប់រងទាំងអស់ ឬអ្នកធានារ៉ាប់រងជាពិសេស ។

**ប្រការ ២៣** : បទប្បញ្ញត្តិទាំងអស់ដែលមានទំនាស់ទៅនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ២៤** : ប្រកាសនេះមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី០១ ខែ០៤ ឆ្នាំ ២០០៥

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

" ដើម្បីជូនជ្រាប "

-ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខៈ ២៩៥.....សហវ.ប្រក.

# ប្រកាស
## ស្តីពី
## ការរំសាយការិយាល័យសវនកម្មផ្ទៃក្នុងរបស់នាយកដ្ឋានពន្ធដារ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញ ព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ៤០ អនក្រ/បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមស្ថាប័នក្រសួងនិងសហគ្រាសសាធារណៈ
- បានឃើញ ប្រកាសលេខ២០៩ សហវ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ៩០០ សហវ.ពដ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការបង្កើតការិយាល័យសវនកម្មផ្ទៃក្នុង នៅក្នុងនាយកដ្ឋានពន្ធដារ

- បានឃើញ ប្រកាសលេខ៩០៤ សហវ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការផ្ទេរភារកិច្ចមន្ត្រីរាជការ
- បានឃើញ ការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច:

**ប្រការ១:** ត្រូវបានរំសាយការិយាល័យសវនកម្មផ្ទៃក្នុងរបស់នាយកដ្ឋានពន្ធដារ និង សំរេចផ្ទេរភារកិច្ច និង តែងតាំងមន្ត្រីរាជការពន្ធដារចំនួន ០៩ រូប របស់ការិយាល័យនេះ ឱ្យទៅបំរើការងារនៅតាមការិយាល័យ និង សាខាពន្ធដារខេត្តនានា នៃនាយកដ្ឋានពន្ធដារ ។

**ប្រការ២:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥

**គាត ឈន់**

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២
- កាលប្បវត្តិ-ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ១៩៥ សហវ.ប្រក

# ប្រកាស

## ស្តីពី

## គោលការណ៍ណែនាំផ្នែកគណនេយ្យ

## សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១០៦ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញការងារចាំបាច់ក្នុងការគ្រប់គ្រងវិស័យធនារ៉ាប់រង ។

## សំរេច

**ប្រការ ១ :** ដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំផ្នែកគណនេយ្យ សំរាប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ។

**ប្រការ ២** : គ្រប់ក្រុមហ៊ុនធានារ៉ាប់រងទូទៅនៅកម្ពុជា ត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុនៃការិយបរិច្ឆេទនៃកិច្ចប្រត្តិបការរបស់ខ្លួនប្រចាំឆ្នាំហិរញ្ញវត្ថុនិមួយៗ (ថ្ងៃទី ១ ខែ មករា- ថ្ងៃទី ៣១ ខែ ធ្នូ) តាមគំរូដូចភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសណែនាំនេះ ដែលរួមមាន បទដ្ឋានអប្បបរមា និង ទំរង់របាយការណ៍ប្រចាំឆ្នាំរៀបចំដោយក្រុមហ៊ុនធានារ៉ាប់រងទូទៅសំរាប់អគ្គនាយក និងសវនករ និង ផ្សព្វផ្សាយអោយសាធារណៈជនដឹងពីតារាងតុល្យការចុងគ្រាប្រចាំឆ្នាំនិមួយៗ ។ ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់ត្រូវមានកាតព្វកិច្ចផ្តល់ពត៌មានច្រើនលើសនេះ ដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៣** : គោលការណ៍អនុវត្តន៍លើគណនេយ្យសំរាប់បុព្វលាភរួមមាន÷

ក. ការទទួលស្គាល់ចំណូលបុព្វលាភ នាដំណាច់ឆ្នាំហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចតទៅ: បុព្វលាភនឹងត្រូវជាចំណូលនៅពេលចាប់ផ្តើមទទួលយកហានិភ័យ ។ បុព្វលាភលើបំណ្ណសន្យារ៉ាប់រង ដែលមានអាយុកាលច្រើនជាង ១២ ខែ ត្រូវផ្តល់ពត៌មានដល់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ បុព្វលាភត្រូវបានចាត់ជាចំណូលលើបំណ្ណសន្យារ៉ាប់រងទាំងនោះ ត្រូវស្របតាមលំនាំហានិភ័យ ។

ខ. តំលៃនៃបុព្វលាភមិនទាន់បង់ រួមទាំង សមតុល្យរបស់ភ្នាក់ងារ និង សមតុល្យធានារ៉ាប់រងបន្តមិនត្រូវច្រើនជាងប្រាក់មិនទាន់សងបន្ទាប់ពីដកចេញនូវសំវិធានធនសំរាប់បំណុលដែលពិបាកទារ ឬ បំណុលសង្ស័យបានឡើយ ។ ក្នុងគោលបំណងនេះ បុព្វលាភមួយចំនួនរួមទាំងសមតុល្យរបស់ភ្នាក់ងារធានារ៉ាប់រង និង សមតុល្យរបស់ធានារ៉ាប់រងបន្តរួមទាំងចំនួនទឹកប្រាក់ ត្រូវធ្វើសំណងតែមិនទាន់បានសងលើសពី ០៦ ខែ គិតចាប់ពីថ្ងៃដែលត្រូវបង់នឹងត្រូវចាត់ទុកថា «បំណុលពិបាកទារ និង បំណុលសង្ស័យ» ។ ចំពោះបំណុលដែលលើសពី ០៦ ខែ ត្រូវមានសំវិធានធននៅក្នុងគណនី ។

គ. ទុនបំរុងសំរាប់បុព្វលាភដែលមិនទាន់ជាចំណូល (ឬហានិភ័យមិនទាន់ផុតកំណត់) សំរាប់ការធានារ៉ាប់រងទូទៅ នឹងត្រូវកំណត់ដោយប្រើប្រាស់វិធីសាស្ត្រសមស្រប ក្នុងការកំណត់បុព្វលាភមិនទាន់កត់ជាចំណូល ដែលអាចទទួលយកបាន ។ ទុនបំរុងសំរាប់ហានិភ័យមិនទាន់ផុតកំណត់នឹងកំណត់ដោយផ្អែកលើមូលដ្ឋាននៃបុព្វលាភដុលដកចេញការធានារ៉ាប់រងបន្ត ដែលបានធានានៅក្នុងកំឡុងពេលនោះ ។ សំរាប់គោលបំណងនេះ ការដកចេញនឹងត្រូវធ្វើឡើងពីបុព្វលាភដុលដោយអនុវត្តលើគ្រប់ការធានារ៉ាប់រងបន្ត រួមទាំងការធានារ៉ាប់រងបន្តនៃហានិភ័យពិសេស និងការធានារ៉ាប់រងបន្ត ដែលប្រាក់បញ្ញើជាទុនបំរុងអប្បបរមានៃការធានារ៉ាប់រងបន្តត្រូវបានរក្សាទុក។

**ប្រការ ៤** : គោលការណ៍អនុវត្តន៍លើគណនេយ្យសំរាប់ប្រាក់សំណងរួមមាន÷

១. សំវិធានធនសំរាប់ប្រាក់សំណងដែលមិនទាន់សងសំរាប់អាជីវកម្មធានារ៉ាប់រងទូទៅ នឹងកំណត់ឱ្យប្រើវិធីសាស្ត្រប្រាក់សំណងមិនទាន់សងដែលអាចទទួលយកបានមួយ ។ ពាក់ព័ន្ធនឹង

សវិធានធនសំរាប់កាតព្វកិច្ចធ្វើសំណងជាលក្ខណៈស្តង់ដារ គឺត្រូវប្រើវិធីសាស្ត្រ ផ្អែកលើករណីជាវិធីសាស្ត្រមូលដ្ឋាន ។ ចំណែកទុនបំរុងអាចត្រូវពិនិត្យឡើងវិញ ដោយប្រើវិធីសាស្ត្រផ្សេងទៀតដូចជាវិធីសាស្ត្រតំលៃជាមធ្យម ឬ វិធីសាស្ត្របមន្ត ដើម្បីវាយតំលៃពីភាពគ្រប់គ្រាន់នៃសវិធានធន ។ វិធីសាស្ត្រគណិតសាស្ត្រនៃការបង្កើតទុនបំរុងសំរាប់ប្រាក់សំណងមិនអាចជំនួសដោយប្រើវិធីសាស្ត្រតាមករណីឡើយ ។

វិធីសាស្ត្រតំលៃមធ្យម ឬ វិធីសាស្ត្របមន្តអាចប្រើបានតែក្នុងកាលៈទេសៈដូចខាងក្រោម៖

ក) សំរាប់ប្រាក់សំណង ដែលមិនមានទិន្នន័យគ្រប់គ្រាន់ ហើយអាចប៉ាន់ស្មានបំណុលបាន

ខ) សំរាប់សវិធានធននៃប្រាក់សំណង « កើតមានប៉ុន្តែមិនរាយការណ៍ »

គ) ដើម្បីពិនិត្យភាពគ្រប់គ្រាន់នៃសវិធានធនទូទៅសំរាប់ប្រាក់សំណងមិនទាន់សង

២. ការរាយការណ៍ប្រាក់សំណង នាដំណាច់ឆ្នាំហិរញ្ញវត្ថុ ត្រូវអនុវត្តដូចតទៅ៖

ក) ប្រាក់សំណងគួរតែត្រូវចុះបញ្ជីនៅក្នុងបញ្ជីប្រាក់សំណង ហើយធ្វើការប៉ាន់ស្មានពីការចំណាយ ជាបន្ទាន់បន្ទាប់ពីបានទទួលដំណឹងជាលើកដំបូង ។

ខ) សវិធានធនសំរាប់ប្រាក់សំណង ត្រូវតែធ្វើឡើងដោយប្រើពតិមានដែលមានទាំងអស់ ហើយសវិធានធនទាំងអស់ត្រូវតែពិនិត្យឡើងវិញ និង ធ្វើការកែតំរូវទៅតាមពតិមានដែលមាន។ ចំពោះចំនួនបំណុលដែលបានផ្តល់លើប្រាក់សំណង ត្រូវតែគិតទៅលើការប៉ាន់ស្មានចំនួនដែលសំរេចផ្តល់អោយបានត្រឹមត្រូវបំផុត ឬ ទូទាត់ដោយផ្អែកលើរាល់ការពិតដែលមាន និងលើការសន្មតនៃបំណុលដែលទទួលយក ។

គ) សវិធានធនសំរាប់ប្រាក់សំណង មិនត្រូវកាត់បន្ថយដោយគ្រាន់តែគកស្ទះឯកសារ ឬអ្នកទាមទារប្រាក់សំណងមិនបានឆ្លើយតបភ្លាមៗ។ សវិធានធននេះ ត្រូវតែរក្សាទុករហូតដល់ប្រាក់សំណងត្រូវបានដកជាពិសេស ឬ ផុតពេលវេលា ។

ឃ) សវិធានធនសំរាប់ប្រាក់សំណង មិនត្រូវលុបចោលទាំងស្រុងដោយគ្រាន់តែក្រុមហ៊ុនធានារ៉ាប់រងធ្វើការបដិសេធសំណងនោះឡើយ។ នៅពេលដែលការទាមទារសំណងមិនមានអ្វីគួរឱ្យសង្ស័យលើសពីទំហំនៃការធានារ៉ាប់រង សវិធានធនអាចនឹងត្រូវកាត់បន្ថយទៅដល់កំរិតមួយដែលអាចទូទាត់តំរៃផ្លូវច្បាប់ ដើម្បីការពារនឹងការចោទប្រកាន់ណាមួយក្នុងករណីណាមានការប្តឹងផ្តល់ទៅដល់តុលាការ ។ សវិធានធននេះអាចលុបចោលបន្ទាប់ពីរយៈពេល ១២ ខែ ប្រសិនបើគ្មានការវិវត្តន៍ណាមួយទេ ។

ង) នៅពេលដែលប្រាក់សំណងត្រូវបានបដិសេធ ដោយមានការបំពានលើកិច្ចសន្យាធានារ៉ាប់រង ឬ លក្ខខណ្ឌនៃការធានាក្រុមហ៊ុនធានារ៉ាប់រង មិនត្រូវដកសំវិធានធនសំរាប់ប្រាក់សំណងចេញពីបញ្ជីរបស់ខ្លួន រហូតដល់ផុតកាលកំណត់នៃការធ្វើសំណង ។ ទោះជាយ៉ាងណាក៏ដោយសំវិធានធនអាចកាត់បន្ថយនៅត្រឹមចំនួនដែលគិតថាគ្រប់គ្រាន់ទៅតាមកាលៈទេសៈនៃការបំពានកិច្ចសន្យា ដោយមានការយល់ព្រមពីអ្នកគ្រប់គ្រងក្រុមហ៊ុន ។

ច) សំវិធានធនលើរាល់ប្រាក់សំណងដែលមិនទាន់សង ត្រូវតែពិនិត្យឡើងវិញយ៉ាងហោចណាស់ក្នុងមួយឆ្នាំម្តង ដោយបុគ្គលិកជំនាញដែលមានបទពិសោធន៍គ្រប់គ្រាន់នៅក្នុងអាជីវកម្ម ។

ឆ) អ្នកគ្រប់គ្រងក្រុមហ៊ុនត្រូវពិនិត្យឡើងវិញជារៀងរាល់ខែ ពីភាពគ្រប់គ្រាន់នៃសំវិធានធនលើប្រាក់សំណងដោយផាត់ទាត់នូវចំនួនដែលបានបង់ជាមួយនឹងសំវិធានធនដែលមានចំពោះសំណង ។ នៅពេលដែលការពិនិត្យឡើងវិញបែបនេះបង្ហាញថា ទុនបំរុងមាននិន្នាការទៅរកភាពមិនគ្រប់គ្រាន់ត្រូវចាត់វិធានការជាបន្ទាន់ ។

ជ) នៅចុងឆ្នាំ អ្នកគ្រប់គ្រងជាន់ខ្ពស់ត្រូវតែធ្វើការពិនិត្យឡើងវិញលើភាពគ្រប់គ្រាន់ទាំងអស់នៃសំវិធានធនដោយប្រើវិធីសាស្ត្រស្ថិតិដូចជាចំណាយមធ្យមលើប្រាក់សំណង ឬលំនាំនៃការប្រែប្រួលប្រាក់សំណង ។

៣. សំវិធានធនដែលសមល្មមសំរាប់ប្រាក់សំណងដែលកើតឡើងតែមិនទាន់រាយការណ៍ (IBNR) ត្រូវកំណត់ ទៅតាមលំនាំប្រាក់សំណងជាក់ស្តែងដែលធ្លាប់មានក្នុងពេលថ្មីៗកន្លងមក ហើយប៉ាន់ស្មានទៅអនាគត ដោយពិចារណាលើកត្តាដូចខាងក្រោម ÷

ក) កំណើននៃអាជីវកម្មដែលរួមមាន បុព្វលាភ ទឹកប្រាក់ធានា ចំនួនហានិភ័យ និងសមាសភាគធុរៈកិច្ច

ខ) ករណីកើតមានសំណង រួមមានចំនួន និង បរិមាណទាក់ទងទៅនឹងទំហំអាជីវកម្ម

គ) ការលេចឡើងនូវប្រាក់សំណងសំរាប់ឆ្នាំដែលធានាបន្តបន្ទាប់ ព្រមទាំងនិន្នាការក្នុងការរាយការណ៍ និង លំនាំនៃការដោះស្រាយទូទាត់ ។

ឃ) ផលប៉ះពាល់ នៃអតិផរណាលើចំនួនប្រាក់សំណង និងការប៉ាន់ស្មានទៅអនាគត និង

ង) ប្រៀបធៀបជាមួយនឹងនិន្នាការទីផ្សារតាមតែអាចធ្វើទៅបាន

៤. នៅពេលកំណត់នូវចំណែកនៃក្រុមហ៊ុនធានារ៉ាប់រងបន្ត នូវប្រាក់សំណងដែលមិនទាន់សង ត្រូវមានការប្រុងប្រយ័ត្ន ដោយមិនរាប់បញ្ចូលក្នុងបំណុលដែលត្រូវទារយកពីក្រុមហ៊ុនធានារ៉ាប់រងបន្ត ក្នុងករណីដែល ÷

ក) ក្រុមហ៊ុនធានារ៉ាប់រងបន្ត មិនអាចសងបំណុលបាន (អសាធនភាព)

ខ) ក្រុមហ៊ុនធានារ៉ាប់រងបន្ត បានបដិសេធចំពោះប្រាក់សំណង ដោយហេតុផលផ្សេងៗ ឬ

គ) ការទាមទារសំណងពីក្រុមហ៊ុនធានារ៉ាប់រងបន្ត មានការលំបាកដោយហេតុផលផ្សេងៗ

**ប្រការ ៥:** ស្តង់ដារគណនេយ្យធានារ៉ាប់រង ជាធម្មតាអនុញ្ញាតអោយក្រុមហ៊ុនធានារ៉ាប់រងទទួលយកហានិភ័យពីបរទេសតាមរយៈសន្ធិសញ្ញា ហើយអាចប្រើប្រាស់វិធីសាស្ត្រធានារ៉ាប់រងចំហ ។

នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងអនុម័តប្រើប្រាស់វិធីសាស្ត្រនេះ ត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន ។ នៅពេលទទួលបានការយល់ព្រម ហើយត្រូវប្រកាន់ខ្ជាប់នូវគោល-ការណ៍ណែនាំដូចខាងក្រោម៖

ក) នៅពេលដែលក្រុមហ៊ុនធានារ៉ាប់រងសំរេចចិត្តប្រើប្រាស់វិធីសាស្ត្រទទួលធានារ៉ាប់រងចំហ ក្រុមហ៊ុនត្រូវតែប្រើវិធីសាស្ត្រគណនេយ្យនេះនៅឆ្នាំជាបន្តបន្ទាប់ ។ ប្រសិនបើក្រុមហ៊ុនធានារ៉ាប់រងមានបំណងប្តូរទៅប្រើវិធីសាស្ត្រគណនេយ្យ តាមឆ្នាំការិយបរិច្ឆេទ ក្រុមហ៊ុនត្រូវតែផ្តល់ហេតុផលសំរាប់ការសំរេចចិត្តផ្លាស់ប្តូរ និង មានការយល់ព្រមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ខ) ឆ្នាំធានារ៉ាប់រងត្រូវតែទុកចំហសំរាប់រយៈពេលអតិបរមា ៣៦ខែ ដែលនៅចុងរយៈកាលនៃឆ្នាំធានានោះ ត្រូវបិទបញ្ជីដោយមានសមតុល្យឥណពន្ធ និងប៉ាន់ប្រមាណពីបំណុលពុំទាន់សងសំរាប់ឆ្នាំនោះឱ្យបានត្រឹមត្រូវ ហើយផ្ទេរបំណុលនិងមូលនិធិដែលមានតំលៃស្មើទៅឆ្នាំធានាចំហបន្ទាប់ ។

គ) ចំណូលទាំងអស់ ដែលត្រូវទទួលបានពីក្រុមហ៊ុនធានារ៉ាប់រង និងចំណាយទាំងអស់ដែលត្រូវទូទាត់ចំពោះក្រុមហ៊ុនធានារ៉ាប់រង ដែលពាក់ព័ន្ធក្នុងប្រតិបត្តិការធានារ៉ាប់រងបន្ត ត្រូវបញ្ចូលជាមូលនិធិ ។ ចំណូលផ្សេងទៀត ដូចជាចំណូលវិនិយោគ ឬ ចំណាយផ្សេងទៀតមិនត្រូវកត់ត្រា ឬ បញ្ចូលក្នុងមូលនិធិទេ ។

ឃ) នៅចុងកាលគណនេយ្យម្តងៗនៃរាល់ឆ្នាំធានារ៉ាប់រងចំហនីមួយៗ ត្រូវមានមូលនិធិគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសំណង ចំពោះហានិភ័យដែលមិនទាន់ផុតរយៈពេលកំណត់ និងកាតព្វកិច្ចចំពោះការទាមទារសំណងដែលពុំទាន់សង (outstanding claim) (រួមមានការទាមទារប្រាក់ IBNR) ។ ប្រសិន បើមូលនិធិនោះត្រូវបានរកឃើញថាមាន

និនភាពត្រូវបំពេញនិនភាពនោះ ឱ្យបានល្អប្រសើរជាបន្ទាន់ ដោយធ្វើការផ្ទេរអោយបាន គ្រប់ចំនួនចូលទៅក្នុងមូលនិធិនោះ ។

ង) ប្រសិនបើមូលនិធិក្លាយជាអវិជ្ជមាន ដោយសារការចំណាយទៅលើបុព្វលាភសំរាប់ការ ការពារអាជីវកម្ម (portfolio) មុនពេលចំណូលបុព្វលាភនៃអាជីវកម្ម (portfolio) ត្រូវទទួលបានមូលនិធិត្រូវរក្សាទុកតុល្យភាពជាវិជ្ជមាន ដោយមិនគិតពីទស្សនៈសុទិដ្ឋិនិយមរបស់ក្រុមហ៊ុន អំពីលទ្ធផលចុងក្រោយដែលត្រូវទទួលបានសំរាប់ឆ្នាំធានារ៉ាប់រង នោះ ។ មូលនិធិនេះត្រូវបង្កើនបន្ថែមទៀតអោយដល់កំរិតគ្រប់គ្រាន់ល្មម ដើម្បីអាចធ្វើ សំណងលើគ្រប់បំណុលទាំងអស់ ។

ច) សំណងសំរាប់ហានិភ័យមិនទាន់ផុតកំណត់ ត្រូវវាយតំលៃផ្អែកលើមូលដ្ឋាននៃការ សន្មតច្បាស់លាស់ដោយស្របតាមបុព្វលាភ ដែលមាននិងបំណុលមិនមានរយៈពេល កំណត់ ដែលទាក់ទងទៅនឹងបុព្វលាភទាំងនេះ ។ ការតព្វកិច្ចសងបំណុលនេះ មិនត្រូវតិច ជាងចំនួន ដែលបានកំណត់ដោយវិធី ១/៨ សំរាប់ប្រភេទអាជីវកម្មមិនមែននាវា សំបកនាវា និង អាកាសចរណ៍ ឬ ២៥ % ចំពោះអាជីវកម្មដឹកទំនិញតាមនាវា ។

ឆ) ប្រាក់សំណងពុំទាន់សង ត្រូវប៉ាន់ប្រមាណចំពោះកិច្ចព្រមព្រៀងនីមួយៗដោយប្រើប្រាស់ មធ្យោបាយល្អបំផុតដែលអាចធ្វើបានផ្អែកលើទិន្នន័យដែលមាន ។ ការប៉ាន់ប្រមាណបែបនេះ ត្រូវបំពេញដោយការវាយតំលៃសមស្របរបស់ IBNR។ ចំពោះគោលបំណងនេះ ក្រុមហ៊ុន ធានារ៉ាប់រងត្រូវពិចារណារៀបចំទិន្នន័យឱ្យដាច់ដោយឡែកពីគ្នា សំរាប់ប្រភេទអាជីវកម្ម នីមួយៗ ដូចជាអគ្គីភ័យ តួនាវា ការដឹកទំនិញតាមនាវា វិស្វកម្ម សំរាប់សន្ធិសញ្ញា សមាមាត្រ ការធានារ៉ាប់រងបន្ត និង សន្ធិសញ្ញាទទួលសងលើសពីការខាត (Excess of loss) ។ ក្រៅពីនេះ ការសិក្សាពីតំរូវរៀបចំការទាមទារប្រាក់សំណងទៅតាមបទពិសោធន៍ ផ្ទាល់របស់ក្រុមហ៊ុនស្របតាមតំរូវទីផ្សារដែលបានបង្កើតឡើង សំរាប់ការទាមទារប្រាក់ សំណង ដោយរៀបចំផ្អែកលើទិន្នន័យដែលមាន ។

**ប្រការ ៦ :** ទ្រព្យសកម្មដែលត្រូវកែតំរូវ ត្រូវកំណត់ដូចខាងក្រោម៖

១. តំលៃទ្រព្យសកម្មដែលជាបន្ទុក ឬ ជាប់សន្យា ឬ ខ្ចីមិនត្រូវរាប់បញ្ចូលទៅក្នុងមូលធនត្រួតពិនិត្យ (Supervisory Capital) ទេ ។ នេះជាការអនុវត្តន៍ទូទៅសំរាប់អ្នកត្រួតពិនិត្យធានារ៉ាប់រង

ដើម្បីកំណត់ ឱ្យបានច្បាស់នូវទ្រព្យសកម្មដែលអាចធានាបាននូវសាធនភាព និង ទុនបំរុងបច្ចេកទេស ។

